**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des sciences Economique**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ទម្រង់នៃលិខិតមតកសាសន៍ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

| | |
|---|---|
| រៀបរៀងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **តាំង ស៊ុយហេង** | លោក **គង់ សុភ័ក្ត្រ** |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ទី ២៧ (អាហារូបករណ៍) | ឆ្នាំសរសេរសារណា ២០២២ |

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋមនាងខ្ញុំ **តាំង ស៊ុយហេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី២៧ (អាហារូបករណ៍) ឆ្នាំសិក្សា ២០១៨-២០២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

**លោកឪពុក** និង **អ្នកម្តាយ** យ៉ាងជ្រាលជ្រៅជាទីបំផុតដែលអ្នកមានគុណបានផ្តល់កំណើតដល់រូបកូនព្រមទាំងខិតខំពុះពារនូវគ្រប់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅកូនតាំងពីមិនទាន់ដឹងក្តីជួយទំនុកបម្រុងទាំងស្មារតី និងសម្ភារៈរហូតទទួលបានការសិក្សាពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សា។

នាងខ្ញុំសូមថ្លែងអំណរគុណផងដែរជូនចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្រៀន ណែនាំដោយយកចិត្តទុកដាក់ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងហើយធ្វើឱ្យនាងខ្ញុំទទួលបាននូវចំណេះដឹង។

ជាពិសេសលោកសាស្ត្រាចារ្យ **គង់ សុភ័ក្រ្ត** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាគ្រូណែនាំក្នុងការសរសេរសារណារបស់នាងខ្ញុំ ហើយលោកបានចំណាយពេលវេលាដ៏មានតម្លៃពន្យល់ ចង្អុលបង្ហាញ និងផ្តល់ជាគំនិតយោបល់ ពិនិត្យមើលនូវខ្លឹមសារ ឱ្យមានការកែសម្រួល ហើយនិងផ្តល់ជាឯកសារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឱ្យសារណានាងខ្ញុំកាន់តែល្អប្រសើរ និងជោគជ័យ។

ជាទីបញ្ចប់នាងខ្ញុំសូមសំដែងនូវការដឹងគុណ និងថ្លែងអំណរគុណចំពោះអ្នកមានគុណទាំងពីរ សាស្ត្រាចារ្យ គង់ សុភ័ក្រ្ត ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រចារ្យ និងបុគ្គលិកទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ដោយមើលឃើញពីបញ្ហា និងវិវាទទាំងឡាយដែលបានកើតឡើងនឹងការធ្វើមតកសាសន៍ដោយមិនមានសុពលភាពត្រឹមត្រូវតាមទម្រង់ដែលបានកំណត់ ជាហេតុធ្វើឱ្យមានការឈ្លោះប្រកែកគ្នា ចំពោះរឿងមត៌កដែលបានបន្សល់ទុកដោយមតកជន ឱ្យទៅសន្តតិជនរបស់ខ្លួន ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី **ទម្រង់នៃលិខិតមតកសាសន៍ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា** មកធ្វើការស្រាវជ្រាវ ដើម្បីធ្វើជាសារណាក្នុងការបញ្ចប់ការសិក្សា។

ការលើកយកប្រធានបទខាងលើនេះ មកធ្វើការស្រាវជាវ ក្នុងគោលបំណង ពង្រីកនូវចំណេះដឹងដែលពាក់ព័ន្ធនឹងប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ ព្រមទាំងជាការចូលរួមចំណែកមួយដល់មិត្តនិស្សិត និងមិត្តអ្នកអានដែលមានគោលបំណងស្វែងយល់ពីទម្រង់ទាំងឡាយដែលកំណត់ដោយច្បាប់ឱ្យបានច្បាស់លាស់ ដោយមានការពន្យល់យ៉ាងលម្អិតពាក់ព័ន្ធនឹងការតាក់តែងនូវមតកសាសន៍ ទម្រង់ចាំបាច់ទាំងឡាយដែលត្រូវមានក្នុងមតកសាសន៍ ព្រមទាំងការថែរក្សានូវមតកសាសន៍នេះឱ្យបានល្អ ដើម្បីជៀសវាង ការក្លែងបន្លំ ឬ កែប្រែនូវមតកសាសន៍ដោយប្រការណាមួយ។ តាមរយៈសារណានេះ នាងខ្ញុំសង្ឃឹមយ៉ាងម៉ុតមាំថា អត្ថបទនេះ នឹងចូលរួមចំណែកមួយក្នុងការផ្សព្វផ្សាយ មិនត្រឹមតែសិស្ស និស្សិតដែលសិក្សាផ្នែកច្បាប់នោះទេ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋទូទៅទាំងអស់ ដើម្បីជាប្រទីបមួយដែលអាចឱ្យងាយយល់ និងងាយយកមកអនុវត្តក្នុងការធ្វើមតកសាសន៍ប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយនូវជម្លោះដណ្តើមទ្រព្យ ព្រមទាំងធ្វើឱ្យសន្តតិជន រួមទាំងបុគ្គលដែលទទួលផលប្រយោជន៍ដោយមតកសាសន៍ អាចរស់នៅបានសុខក្សេមក្សាន្តនៅក្នុងសង្គម ។

ជាចុងក្រោយ នាងខ្ញុំសូមអភ័យទោស ទុកជាមុននូវកំហុសខុសឆ្គង ដែលកើតមានឡើងទាំងបច្ចេកទេស និងខ្លឹមសារ។ សូមសាស្ត្រាចារ្យ សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានមេត្តាយោគយល់អធ្យាស្រ័យ។ នាងខ្ញុំ រីករាយទទួលនូវការកែលំអពីលោកអ្នក។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១៖**

**សញ្ញាណទូទៅ នៃមតកសាសន៍**

**ផ្នែកទី១៖ និយមន័យ និងលក្ខណៈ នៃមតកសាសន៍** ............ ៣

**កថាខណ្ឌទី១៖ និយមន័យ** ............ ៣

**កថាខណ្ឌទី២៖ លក្ខណៈនៃមតកសាសន៍** ............ ៤

១. សកម្មភាពឯកតោភាគី ............ ៤

២. ពេលបង្កើតអានុភាពនៃមតកសាសន៍ ............ ៤

៣. ភាពចាំបាច់នៃទម្រង់ដែលកំណត់ដោយច្បាប់ ............ ៤

៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍ ............ ៥

៥. សកម្មភាពផ្ទាល់ខ្លួន និងផ្តាច់មុខ ............ ៥

**ផ្នែកទី២៖ លក្ខខណ្ឌគ្រឹះនៃមតកសាសន៍** ............ ៥

**កថាខណ្ឌទី១៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍** ............ ៦

១. សមត្ថភាពក្នុងការធ្វើសកម្មភាព ............ ៦

២. សមត្ថភាពខាងឆន្ទៈ ............ ៧

**កថាខណ្ឌទី២៖ ការបង្ហាញឆន្ទៈដោយគ្មានវិការៈ** ............ ៨

១. ការភាន់ច្រឡំ ............ ៨

២. ការឆបោក ............ ៩

៣. ការគម្រាមកំហែង ............ ៩

៤. ព័ត៌មានមិនពិត ............ ៩

៥. ការរំលោភបំពានលើស្ថានភាព ............ ១០

**ផ្នែកទី៣៖ ភាពចាំបាច់នៃទម្រង់មតកសាសន៍** ............ ១០

**កថាខណ្ឌទី១៖ សុពលភាពនៃទម្រង់** ............ ១០

**កថាខណ្ឌទី២៖ ការចុះកាលបរិច្ឆេទ** ............ ១១

## ជំពូកទី២៖

## មតកសាសន៍ តាមទម្រង់ធម្មតា

**ផ្នែកទី១៖ មតកសាសន៍ដោយលិខិតយថាភូត** ..........១៣

**កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍** ..........១៣

១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ..........១៤

២. ទម្រង់ចាំបាច់ នៃមតកសាសន៍ ..........១៤

**កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍** ..........១៦

១. និទ្ទេសដែលត្រូវចុះ ..........១៦

២. ការរក្សាមតកសាសន៍ ..........១៦

**ផ្នែកទី២៖ មតកសាសន៍ដោយលិខិតឯកជន** ..........១៧

**កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍** ..........១៧

១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ..........១៧

២. ទម្រង់ចាំបាច់ នៃមតកសាសន៍ ..........១៨

**កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍** ..........១៩

១. និទ្ទេសដែលត្រូវចុះ ..........១៩

២. ការរក្សាមតកសាសន៍ ..........១៩

**ផ្នែកទី៣៖ មតកសាសន៍ដោយលិខិតសម្ងាត់** ..........២០

**កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍** ..........២០

១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ..........២០

២. ទម្រង់ចាំបាច់ នៃមតកសាសន៍ ..........២១

**កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍** ..........២២

១. និទ្ទេសដែលត្រូវចុះ ..........២២

២. ការរក្សាមតកសាសន៍ ..........២២

## ជំពូកទី៣៖

## មតកសាសន៍ តាមទម្រង់ពិសេស

**ផ្នែកទី១៖ មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**.....២៣
**កថាខណ្ឌទី១៖ ទម្រង់នៃការតាក់តែងមតកសាសន៍** ....................................................២៣
១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ..........................................................២៣
២. ទម្រង់ចាំបាច់នៃមតកសាសន៍ ..............................................................................២៤
**កថាខណ្ឌទី២៖ លក្ខខណ្ឌអានុភាពនៃទម្រង់** ..........................................................២៤
**ផ្នែកទី២៖ មតកសាសនៃជនដែលត្រូវជាប់ឃុំឃាំង និងនៅក្នុងនាវា ឬយន្តហោះ**..២៥
**កថាខណ្ឌទី១៖ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង** ..........................................២៥
១. ទម្រង់នៃការតាក់តែងមតកសាសន៍ ........................................................................២៥
២. លក្ខខណ្ឌអានុភាពនៃទម្រង់ ..................................................................................២៦
**កថាខណ្ឌទី២៖ ជនដែលនៅក្នុងនាវា ឬយន្តហោះ** ....................................................២៧
១. ទម្រង់នៃការតាក់តែងមតកសាសន៍ ........................................................................២៧
២. លក្ខខណ្ឌអានុភាពនៃទម្រង់ ..................................................................................២៨
**ផ្នែកទី៣៖ មតកសាសន៍ ក្នុងស្ថានភាពពិសេសផ្សេងទៀត** ..........................................២៨
**កថាខណ្ឌទី១៖ មតកសាសន៍នៃជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ** ...........២៩
១. លក្ខខណ្ឌសះស្បើយពីជម្ងឺ ..................................................................................២៩
២. វត្តមានវេជ្ជបណ្ឌិត ................................................................................................៣០
**កថាខណ្ឌទី២៖ មតកសាសន៍នៃជនដែលមិនអាចនិយាយបាន ឬមិនអាចស្តាប់បាន**...៣០
១. ម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន ............................................................៣០
២. ម្ចាស់បណ្តាំជាជនដែលមិនអាចស្តាប់បាន ................................................................៣១
**កថាខណ្ឌទី៣៖ មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស** ..........................................៣១
**សេចក្តីសន្និដ្ឋាន** ......................................................................................................៣៣
**អនុសាសន៍**................................................................................................................៣៣
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

មនុស្សគ្រប់រូបនៅក្នុងសង្គម ត្រូវបានទទួលឋានៈក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ដោយមានសមត្ថភាពទទួលបាននូវសិទ្ធិ តាំងពីពេលចាប់កំណើត និងរលត់នូវសមត្ថភាពទទួលសិទ្ធិទៅវិញ នៅពេលដែលទទួលមរណភាព។

បុគ្គលគ្រប់រូបបានផ្សាភ្ជាប់នូវទំនាក់ទំនងរបស់ខ្លួន និងសង្គមតាំងពីខ្លួនបានចាប់កំណើតមក និងបន្តជាបន្តបន្ទាប់ ដោយបានបង្កើតនូវទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនជាច្រើន ក្នុងការរស់នៅប្រចាំថ្ងៃ។ មានបុគ្គលខ្លះ នៅពេលដែលខ្លួននៅរស់ ខ្លួនបានខិតខំប្រឹងប្រែង ធ្វើការ រកស៊ី បានបន្សល់ទុកនូវទ្រព្យសម្បត្តិជាច្រើន ជាទ្រព្យសកម្ម ហើយក៏មានបុគ្គលមួយចំនួន បែរជាបានបន្សល់នូវទ្រព្យអកម្ម ដោយជំពាក់បំណុលម្ចាស់បំណុលជាច្រើន។ ជាគោលការណ៍ច្បាប់ នៅពេលដែលបុគ្គលម្នាក់បានទទួលមរណភាពទៅ បុគ្គលនោះនឹងបាត់បង់នូវសមត្ថភាពទទួលសិទ្ធិ ហើយរាល់សិទ្ធិ និងករណីយកិច្ចទាំងអស់ នឹងត្រូវបន្តទៅបុគ្គលជំនាន់ក្រោយតាមរយៈការធ្វើសន្តតិកម្ម។ អ្នកស្លាប់ដែលបានបន្សល់ទ្រព្យសម្បត្តិ ហៅថា "មតកជន" ចំណែកឯបុគ្គលដែលទទួលសន្តតិកម្ម ហៅថា "សន្តតិជន"។

សន្តតិកម្ម ក្នុងន័យនៃច្បាប់ គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។[1]

ជាគោលការណ៍នៃរបបសន្តតិកម្មនាពេលបច្ចុប្បន្ន គឺមានគោលការណ៍ធំៗចំនួនពីរគឺ គោលការណ៍ជម្រះបញ្ជី និងគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ របបសន្តតិកម្មដោយគោលការណ៍ជម្រះបញ្ជី គឺត្រូវធ្វើការជម្រះបញ្ជីទាំងអស់នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន មុននឹងសន្តតិជនទទួលបន្តនូវទ្រព្យសម្បត្តិដែលជាមត៌ក ប៉ុន្តែនីតិវិធីនេះមានលក្ខណៈស្មុគស្មាញ និងប្រើប្រាស់រយៈពេលយូរ។ ចំណែកឯ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ ជារបបសន្តតិកម្មដែលរាល់សិទ្ធិ និងករណីកិច្ចរបស់មតកជន នឹងត្រូវផ្ទេរបន្តដោយស្វ័យប្រវត្តិទៅសន្តតិជន ប្រសិនបើសន្តតិជនយល់ព្រមទទួលមត៌ក។

សន្តតិកម្មដោយគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ត្រូវបានយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន តាមរយៈក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលចាប់ពីពេលនេះតទៅ ហៅថា "ក្រមរដ្ឋប្បវេណី"។

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ២១, លេខ ១៤៣

សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន។[2] តាមរយៈមាត្រា ១១៤៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានចែងថា "សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ"។

ក្នុងករណីដែលមតកជន មិនបានបង្ហាញឆន្ទៈក្នុងការចាត់ចែងនូវទ្រព្យរបស់ខ្លួនឱ្យសន្តតិជនទេ មត៌កទាំងនោះ នឹងត្រូវផ្ទេរឱ្យសន្តតិជនដោយសន្តតិកម្មតាមបញ្ញត្តិច្បាប់។ ដោយឡែក ការធ្វើសន្តតិកម្មមានបណ្តាំជាករណីដែលមតកជនបានបង្ហាញឆន្ទៈផ្ទេរទ្រព្យរបស់ខ្លួន ដោយចាត់ចែងទ្រព្យសម្បត្តិឱ្យសន្តតិជន ឬ បុគ្គលដទៃក្រៅពីសន្តិជន ដោយបានបន្សល់នូវលិខិតបណ្តាំ ដែលហៅថា "មតកសាសន៍"។

មានបញ្ហាជាច្រើនបានកើតឡើង ចំពោះការទទួលបន្តនូវមត៌ក របស់ជនដែលបានទទួលមរណភាពទៅតាមរយៈលិខិតបណ្តាំ ដោយសារលិខិតបណ្តាំមួយចំនួនពុំបានធ្វើឡើងត្រឹមត្រូវ និងពុំមានអនុភាពតាមផ្លូវច្បាប់។ ប្រជាពលរដ្ឋមួយចំនួន ពុំបានយល់ដឹងអំពីការធ្វើលិខិតមតកសាសន៍ តាមទម្រង់ឱ្យបានត្រឹមត្រូវនោះទេ ដែលករណីខ្លះគ្រាន់តែសរសេរបែងចែក ដោយមិនមានភាពច្បាស់លាស់ មិនបានបំពេញលក្ខខណ្ឌចាំបាច់ទាំងឡាយដែលច្បាប់តម្រូវ និងខ្លះទៀតមតកជន បានបង្ហាញឆន្ទៈចុងក្រោយនៅពេលដែលខ្លួនជិតទទួលមរណភាព ហើយបុគ្គលផ្សេងទៀត ពុំបានដឹងពីលក្ខខណ្ឌទម្រង់ចាំបាច់ដែលត្រូវធ្វើ និងនីតិវិធីដែលត្រូវធ្វើបន្ទាប់ពីម្ចាស់បណ្តាំបានទទួលមរណភាពជាដើម។

ទាំងនេះ សុទ្ធតែជាបញ្ហាដែលបានកើតឡើងនៅក្នុងសង្គមជាក់ស្តែង ការណ៍នេះបានធ្វើឱ្យការបង្ហាញឆន្ទៈចុងក្រោយរបស់មតកជន បែរជាពុំអាចបង្កើតអានុភាពតាមផ្លូវច្បាប់ និងមិនអាចយកទៅអនុវត្តបានឡើយ ហើយក៏ជាកត្តា ដែលនាងខ្ញុំលើកយកនូវទម្រង់នៃលិខិតបណ្តាំទាំងអស់ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃកម្ពុជា ដែលកំពុងអនុវត្តក្នុងសង្គមជាក់ស្តែង មកសិក្សាវែកញែកជាប្រធានបទដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ក្នុងការសិក្សាលើប្រធានបទស្តីពី **"ទម្រង់នៃលិខិតមតកសាសន៍ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា"** យើងនឹងធ្វើការបែងចែកជាបី (០៣) ជំពូក គឺ

ជំពូកទី១ **សញ្ញាណទូទៅ នៃលិខិតមតកសាសន៍**

ជំពូកទី២ **លិខិតមតកសាសន៍ តាមទម្រង់ធម្មតា**

ជំពូកទី៣ **លិខិតមតកសាសន៍ តាមទម្រង់ពិសេស**

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី១

# ជំពូកទី១៖
# សញ្ញាណទូទៅ នៃមតកសាសន៍

មតកសាសន៍ ជាលិខិតបណ្តាំដែលត្រូវបានបង្កើតឡើងដោយមតកជន ដើម្បីបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួន មុនពេលទទួលមរណភាពទៅ ក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិដល់សន្តតិជន ឬ អច្ច័យលាភីណាម្នាក់។ មតកសាសន៍បង្កើតអានុភាពនៅពេលដែលមតកជនទទួលមរណភាព។

មុនឈានដល់ការសិក្សាស៊ីជម្រៅ លើទម្រង់សំខាន់ៗទាំងអស់ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី យើងត្រូវដឹងអំពីសញ្ញាណ និងគោលការណ៍ទូទៅ នៃលិខិតមតកសាសន៍ជាមុនសិន។ ក្នុងជំពូកនេះ យើងនឹងធ្វើការសិក្សាស្រាវជ្រាវ និងបែងចែកជាបី (០៣) ផ្នែក គឺ (ផ្នែកទី១) ការកំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃលិខិតមតកសាសន៍ និងលក្ខណៈនៃមតកសាសន៍, (ផ្នែកទី២) លក្ខខណ្ឌគ្រឹះ ក្នុងការបង្កើតនូវលិខិតមតកសាសន៍ និង(ផ្នែកទី៣) ភាពចាំបាច់ នៃទម្រង់មតកសាសន៍។

## ផ្នែកទី១៖ និយមន័យ និងលក្ខណៈ នៃមតកសាសន៍

### កថាខណ្ឌទី១៖ និយមន័យ

មតកសាសន៍ **(Testament/will)** សំដៅដល់លិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងក្រោមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍បន្ទាប់ពីមរណភាព។[3] តាមន័យនេះ មតកសាសន៍ យើងអាចហៅថាជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើង នៅពេលដែលខ្លួននៅមានជីវិត ដោយសម្រេច និងបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួនក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិទាំងឡាយដែលខ្លួនមាន។ ច្បាប់ពុំបានកម្រិតការចាត់ចែងនូវទ្រព្យសម្បត្តិ ចំពោះតែសន្តតិជនរបស់ខ្លួនទេ ប៉ុន្តែអាចជាតតិយជនផ្សេងទៀតតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

មតកសាសន៍ ចាំបាច់ត្រូវធ្វើឡើងក្រោមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី បើមិនដូច្នេះទេ មតកសាសន៍នឹងមិនមានអានុភាពតាមផ្លូវច្បាប់ឡើយ។ ម្ចាស់បណ្តាំ មានសេរីភាពពេញលេញ ក្នុងការចាត់ចែងទ្រព្យរបស់ខ្លួន តាមរយៈមតកសាសន៍ ដោយខ្លួនអាចបង្ហាញឆន្ទៈធ្វើការកែប្រែ ឬ លុបចោល នូវមតកសាសន៍បានដោយសេរី ហើយមតកសាសន៍ចុងក្រោយ ដែលមានកំណត់កាលបរិច្ឆេទចុងក្រោយនឹងបង្កើតអានុភាពតាមផ្លូវច្បាប់។

ដូចបានជម្រាបជូនខាងលើ ក្រៅពីសន្តតិជនម្ចាស់បណ្តាំក៏អាចធ្វើការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ១៧, លេខ ១១៨

ឱ្យទៅបុគ្គលដទៃបានដែរ។ ដែលនេះគេហៅថា "**អច្ច័យទាន**"[4] (**Testamentary Gift**) ហើយអ្នកដែលទទួលបានអច្ច័យទាន គេហៅថា "អច្ច័យលាភី"[5] (**Testamentary donee**)។ អច្ច័យទាន គឺជាប្រព័ន្ធការផ្ទេរ ឬ ការផ្តល់នូវទ្រព្យណាមួយ ឬ តាមភាគចំណែកណាមួយទៅឱ្យបុគ្គលណាម្នាក់ តាមរយៈលិខិតមតកសាសន៍។

**កថាខណ្ឌទី២៖ លក្ខណៈនៃមតកសាសន៍**

មតកសាសន៍មានលក្ខណៈ (១) ជាសកម្មភាពឯកតោភាគី, (២) ពេលដែលត្រូវបង្កើតអានុភាព, (៣) ត្រូវធ្វើតាមទម្រង់ដែលកំណត់ដោយច្បាប់, (៤) ចំណុចដែលត្រូវសរសេរ ត្រូវបានកំណត់ដោយច្បាប់ និង (៥) ជាសកម្មភាពផ្ទាល់ខ្លួន និងផ្តាច់មុខ។

**១. សកម្មភាពឯកតោភាគី**

សកម្មភាពឯកតោភាគី (**Unilateral Act**) គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់។[6] អនុភាពនៃមតកសាសន៍ ត្រូវបានបង្កើតឡើងដោយការសម្តែងឆន្ទៈរបស់ម្ចាស់បណ្តាំតែឯកឯង ដោយមិនមានចូលរួមបង្ហាញឆន្ទៈពីភាគីម្ខាងទៀតឡើយ។ ដូចនេះ មតកសាសន៍ជាសកម្មភាពជាឯកតោភាគី។

**២. ពេលបង្កើតអានុភាពនៃមតកសាសន៍**

មតកសាសន៍ ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំទទួលមរណភាព។[7] នៅពេលដែលម្ចាស់បណ្តាំនៅរស់ ម្ចាស់បណ្តាំមានសិទ្ធិកែប្រែ ឬ លុបចោលនូវមតកសាសន៍មួយផ្នែក ឬ ទាំងមូល ឬ បង្កើតមតកសាសន៍ណាមួយផ្សេងទៀតបាន។ មតកសាសន៍ ដែលមានកាលបរិច្ឆេទចុងក្រោយ នឹងបង្កើតអានុភាពតាមផ្លូវច្បាប់ ក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។

**៣. ភាពចាំបាច់នៃទម្រង់ដែលកំណត់ដោយច្បាប់**

មតកសាសន៍ នឹងបង្កើតអានុភាពនៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ហើយមតកសាសន៍នឹងមិនមានអ្នកណាអាចបញ្ជាក់ភាពត្រឹមត្រូវ និងឆន្ទៈរបស់មតកជន ចំពោះមតកសាសន៍បានទៀតទេ។ ដូច្នេះ ការបង្កើតនូវលិខិតមតកសាសន៍ដាច់ខាត ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ២៦, លេខ ១៧៧
[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ២៦, លេខ ១៨០
[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣១២ កថាខណ្ឌទី១
[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៤ កថាខណ្ឌទី១

ដើម្បីបញ្ជាក់ភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៃលិខិត ព្រមទាំងអាចការពារការក្លែងបន្លំ ឬ កែប្រែមតកសាសន៍ដោយបុគ្គលណាមួយ។

**៤. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍**

ក្នុងការតាក់តែងមតកសាសន៍ ចំណុចសំខាន់ៗមួយចំនួនចាំបាច់ត្រូវសរសេរឱ្យបានច្បាស់លាស់នៅក្នុងមតកសាសន៍ ដូចជាការកំណត់ចំណែកមត៌ក ការកំណត់ពីវិធីក្នុងការបែងចែកមត៌ក ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ ជាដើម។ ចំណុចទាំងនេះ សុទ្ធតែជាចំណុចដែលត្រូវបានកំណត់ដោយច្បាប់ ដោយហេតុថាមតកសាសន៍ គឺមានការបង្ហាញឆន្ទៈតែភាគីម្ខាងតែប៉ុណ្ណោះ ហេតុនេះ វាមានភាពចាំបាច់ណាស់ដែលតម្រូវឱ្យម្ចាស់បណ្តាំលម្អិត ឬ សរសេរឱ្យបានច្បាស់លាស់ នូវចំណុចសំខាន់ៗទាំងនេះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការអនុវត្តមតកសាសន៍នាពេលអនាគត។

**៥. សកម្មភាពផ្ទាល់ខ្លួន និងផ្ទាល់មុខ**

មតកសាសន៍ ជាលិខិតដែលធ្វើឡើងក្នុងការបង្ហាញឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំ។ លិខិតនេះចាំបាច់ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ ដោយឆន្ទៈរបស់ខ្លួនពិតប្រាកដ ក្នុងការចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនអាចមានអ្នកណាតំណាងជំនួស និងមិនត្រូវមានអ្នកបង្ខំ ឬ គំរាមនោះឡើយ។ ម៉្យាងវិញទៀតម្ចាស់បណ្តាំត្រូវតែជានីតិជន ឬ អនីតិជនដែលទទួលបានអត្តាធីនភាព ទើបអាចធ្វើបណ្តាំបាន។ កាលបើម្ចាស់បណ្តាំ ជាជននៅក្រោមអាណាព្យាបាលទូទៅ ខ្លួនអាចធ្វើមតកសាសន៍បាន លុះត្រាតែម្ចាស់បណ្តាំបែរជាសះស្បើយ និងមានសមត្ថភាពដឹងខុសត្រូវ និងអាចវិនិច្ឆ័យ ពីផលវិបាកគតិយុត្តតាមផ្លូវច្បាប់នៅពេលខ្លួនធ្វើលិខិតមតកសាសន៍។

## ផ្នែកទី២៖ លក្ខខណ្ឌគ្រឹះនៃមតកសាសន៍

លក្ខខណ្ឌគ្រឹះ ជាលក្ខខណ្ឌចាំបាច់ក្នុងការបង្កើតមតកសាសន៍ ឱ្យបានត្រឹមត្រូវ និងមានសុពលភាពតាមផ្លូវច្បាប់។ មតកសាសន៍ គឺជាលិខិតរបស់ម្ចាស់បណ្តាំដែលបានបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួន និងមានភាពចាំបាច់ក្នុងការអនុវត្ត នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។ ដូចបានរៀបរាប់ខាងលើ មតកសាសន៍ ត្រូវបានធ្វើឡើងដោយសកម្មភាពឯកតោភាគី ដោយគ្រាន់តែមានការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំតែប៉ុណ្ណោះ មិនចាំបាច់មានការឯកភាព ពីអ្នកទទួលមត៌កនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ម្ចាស់បណ្តាំត្រូវមានលក្ខណៈគ្រប់គ្រាន់ និងមានសមត្ថភាពពេញលេញក្នុងការធ្វើមតកសាសន៍ត្រឹមត្រូវស្របតាមច្បាប់ (កថាខណ្ឌទី១) ព្រមទាំងបង្ហាញឆន្ទៈត្រឹមត្រូវស្របតាមការសម្រេចចិត្តរបស់ខ្លួន និងគ្មានវិការៈណាមួយកើតឡើង (កថាខណ្ឌទី២) ដើម្បីឱ្យមតកសាសន៍មានសុពលភាពតាមផ្លូវច្បាប់។

**កថាខណ្ឌទី១៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍**

ដើម្បីឲ្យមតកសាសន៍មានអានុភាព ម្ចាស់បណ្តាំ ត្រូវតែជាជនដែលមានសមត្ថភាពពេញលេញ ក្នុងការធ្វើសកម្មភាព (១) និងមានសមត្ថភាពខាងឆន្ទៈ (២)។

**១. សមត្ថភាពក្នុងការធ្វើសកម្មភាព**

សកម្មភាព សំដៅដល់កិច្ចសន្យា និងសកម្មភាពឯកតោភាគី។[8] ផ្អែកតាមក្រមរដ្ឋប្បវេណី រូបវន្តបុគ្គលមានដូចជា នីតិជន អនីតិជនដែលមានអត្តាធីនភាព អនីតិជន ជននៅក្រោមអាណាព្យាបាល និងជននៅក្រោមហិតូបត្ថម្ភ។ អនីតិជន ជននៅក្រោមអាណាព្យាបាល និងជននៅក្រោមហិតូបត្ថម្ភ សុទ្ធតែជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។[9] មានន័យថា សមត្ថភាពក្នុងធ្វើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី រួមទាំងសមត្ថភាពក្នុងការធ្វើមតកសាសន៍ របស់ជនទាំងនេះមិនអាចធ្វើសកម្មភាពតាមការសម្រេចរបស់ខ្លួនឡើយ ដោយតម្រូវឲ្យមានការអនុញ្ញាតិពីអ្នកតំណាងដែលច្បាប់បានកំណត់។

ដោយឡែក បុគ្គលដែលជានីតិជន (ក) និងអនីតិជនដែលបានអត្តាធីនភាព (ខ) ជាជនដែលមានសមត្ថភាពពេញលេញក្នុងការធ្វើមតកសាសន៍បាន។[10]

**ក. នីតិជន**

បុគ្គលគ្រប់រូបជានីតិជន សុទ្ធតែអាចធ្វើមតកសាសន៍បាន ឱ្យតែជននោះមានសមត្ថភាពនៅពេលធ្វើមតកសាសន៍។ នីតិជន មានន័យថា ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។[11]

សម្រាប់មតកសាសន៍ មានលក្ខណៈខុសប្លែកពីសកម្មភាពផ្សេង ទោះបីនីតិជនជាជនស្ថិតនៅក្រោមហិតូបត្ថម្ភ ឬ ជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចធ្វើមតកសាសន៍បានដែរ។ ប៉ុន្តែចំពោះការធ្វើមតកសាសន៍ដោយជននៅក្រោមអាណាព្យាបាលទូទៅ ចាំបាច់ត្រូវមានសមត្ថភាពខាងឆន្ទៈ ដោយខ្លួនបានជាសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន និងមានការបញ្ជាក់ត្រឹមត្រូវពីវេជ្ជបណ្ឌិត តាមលក្ខខណ្ឌនៃមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណី។

ការទទួលស្គាល់ឱ្យអ្នកដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពឱ្យធ្វើមតកសាសន៍ ដោយសារតែមតកសាសន៍នឹងមានអានុភាព ក្រោយពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព បានទទួល

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៥

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៨ កថាខណ្ឌទី១

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ១០, លេខ ៧០ ចំណុច ២

មរណភាព ដូច្នេះអានុភាពនៃមតកសាសន៍ មិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ។ ម៉្យាងទៀត មតកសាសន៍ធ្វើឡើងដើម្បីចាត់ចែងទ្រព្យសម្បត្តិដែលមាន គឺមិនមែនដើម្បីឱ្យខ្ចីទ្រព្យថ្មីទៀតជាអាទិ៍ទេ។[12] លើសពីនេះទៀត សកម្មភាពក្នុងការធ្វើមតកសាសន៍ ដែលបានធ្វើឡើងដោយជននៅក្រោមអាណា-ព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ នោះអ្នកអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ មិនអាចលុបមតកសាសន៍នេះចោលបានទេ។[13]

### ខ. អនីតិជនដែលបានអត្តាធីនភាព

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[14] ដោយឡែក ចំពោះអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ហើយខ្លួនអាចទ្រទ្រង់ ជីវភាពខ្លួនឯងដោយឯករាជ្យ នោះតុលាការអាចប្រកាសនូវអត្តាធីនភាពចំពោះបុគ្គលនោះបាន តាមពាក្យសុំរបស់អនីតិជន ដោយមានការសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។ បន្ថែមពីនេះ ក្នុងករណីដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍រួច ទោះបីមិនមានការប្រកាសរបស់តុលាការក្តី ក៏អនីតិជនទទួលបានអត្តាធីនភាពដែរ។

ក្នុងករណីដែលអនីតិជនដែលទទួលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា តាមរយៈការប្រកាសរបស់តុលាការក្តី តាមការរៀបអាពាហ៍ពិពាហ៍ក្តី ត្រូវបានចាត់ទុកថា បុគ្គលនោះបានដល់នីតិភាព។[15] ហេតុនេះ អនីតិជនដែលត្រូវបានទទួលអត្តាធីនភាព អាចធ្វើសកម្មភាពផ្សេងៗរួមទាំងមតកសាសន៍ បានពេញលេញដូចនីតិជនផងដែរ។

### ២. សមត្ថភាពខាងឆន្ទៈ

ម្ចាស់បណ្តាំធ្វើបណ្តាំ គឺក្នុងគោលបំណងសម្តែងនូវការសម្រេចចិត្តចុងក្រោយរបស់ខ្លួនដើម្បីផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនឱ្យទៅសន្តតិជន និងដើម្បីកុំឱ្យកើតមានជម្លោះរវាងសហសន្តតិជន នៅពេលខ្លួនបានទទួលមរណភាព។ ដូច្នេះ ការកំណត់សមត្ថភាពខាងឆន្ទៈនៅពេលធ្វើមតកសាសន៍ជារឿងសំខាន់ ប្រសិនបើពុំដូច្នេះទេ មតកសាសន៍នឹងមិនមានសុពលភាពឡើយ ជាហេតុនាំឲ្យពុំអាចសម្រេចតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

ផ្អែកតាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណី បានចែងថា "សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាននំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន អាចលុបចោល

[12] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, ភាគ ៦ ទំព័រ ៣០

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៨ កថាខណ្ឌទី២

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៧

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២

បាន"។ ទោះបីមិនមែនជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏អាចលុបចោលសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនបានដែរ។

ចំពោះការធ្វើមតកសាសន៍ ក៏ដូចគ្នាដែរ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈនៅពេលធ្វើមតកសាសន៍។ សមត្ថភាពខាងឆន្ទៈ សំដៅដល់ ស្ថានភាពដែលបុគ្គលអាចត្រិះរិះគិតពិចារណា ទៅលើអំពើណាមួយដែលខ្លួនធ្វើ ហើយបុគ្គលដែលបានធ្វើសកម្មភាព អាចមើលឃើញជាមុននូវលទ្ធផលផ្លូវច្បាប់ ដែលកើតចេញពីអំពើរបស់ខ្លួន។ មានន័យថា បុគ្គលដែលបានធ្វើសកម្មភាព គឺពិតជាបានដឹង និងអាចវិនិច្ឆ័យចំពោះសកម្មភាពដែលខ្លួនបានធ្វើ។ ការខ្វះសមត្ថភាពក្នុងការយល់ដឹង ឬ វិនិច្ឆ័យ អាចកើតឡើងដោយសារបញ្ហាផ្នែកបញ្ញាស្មារតី ដោយសារស្ថានភាពពិសេសណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍ ការគិតការពិចារណារបស់បុគ្គល ឬ ដោយសារស្ថានភាពជម្ងឺផ្លូវចិត្ត ឬ មានបញ្ហាដោយសារការប្រើប្រាស់ថ្នាំលើសកំណត់ជាដើម។

បុគ្គលណាដែលបានដឹងថា ម្ចាស់បណ្តាំបានធ្វើមតកសាសន៍ដោយខ្វះសមត្ថភាព ដោយមិនអាចយល់ដឹង ឬ វិនិច្ឆ័យបានដោយស្ថិតក្នុងស្ថានភាពណាមួយ បុគ្គលនោះត្រូវផ្តល់ភស្តុតាងអំពីហេតុនោះ។

### កថាខណ្ឌទី២៖ ការបង្ហាញឆន្ទៈដោយគ្មានវិការៈ

វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា ក៏ត្រូវអនុវត្តចំពោះសកម្មភាពឯកតោភាគី។[16] តាមអត្ថន័យនេះ បញ្ញត្តិដែលពាក់ព័ន្ធនឹងវិការៈនៃការបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យា ត្រូវបានយកមកអនុវត្តចំពោះមតកសាន៍ផងដែរ ព្រោះមតកសាសន៍ជាសកម្មភាពឯកតោភាគី។ មតកសាសន៍ ដែលធ្វើឡើងដោយការបង្ហាញឆន្ទៈមានវិការៈ អាចជាកម្មវត្ថុនៃការលុបចោល ឬ មោឃភាពបាន។

ទោះបីជាម្ចាស់បណ្តាំជានីតិជន ឬ ជាអនីតិជនដែលទទួលបានអត្តាធីនភាព បានធ្វើមតកសាសន៍តាមកំណត់ច្បាប់ និងមានសមត្ថភាពខាងឆន្ទៈត្រឹមត្រូវក៏ដោយ ក៏ មតកសាសន៍នឹងមិនបង្កើតសពុលភាពតាមច្បាប់ទេ ប្រសិនម្ចាស់បំណ្តាំបានបង្ហាញឆន្ទៈដោយ (១) ការភាន់ច្រឡំ (២) ការឆបោក (៣) ការគំរាមកំហែង (៤) ការបង្ហាញការមិនពិត និង (៥) ការរំលោភលើស្ថានភាព។

#### ១. ការភាន់ច្រឡំ

ការភាន់ច្រឡំ គឺសកម្មភាពដែលម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈផ្ទុយពីបំណងរបស់ខ្លួន ហើយប្រសិនបើម្ចាស់បណ្តាំ បានដឹងពីការភាន់ច្រឡំនោះ នឹងមិននាំឱ្យមានការការបង្កើតមតកសាសន៍ឡើយ។ ប៉ុន្តែ

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣១២ កថាខណ្ឌទី២

ជាគោលការណ៍ច្បាប់ មិនមែនដោយសារតែការភាន់ច្រឡំរបស់ម្ចាស់បណ្តាំតែម្ខាង អាចអះអាងអំពីវិការៈនៃការបង្ហាញឆន្ទៈ និងយកជាមូលហេតុដើម្បីលុបចោលមតកសាសន៍បានឡើយ។ ការភាន់ច្រឡំរបស់ម្ចាស់បណ្តាំអាចយកមកធ្វើជាមូលហេតុនៃការលុបចោលមតកសាសន៍ គឺជាសកម្មភាពដែលម្ចាស់បណ្តាំមានការភាន់ច្រឡំលើចំណុចសំខាន់ៗ នៃមតកសាសន៍ ហើយភាគីម្ខាងទៀត ដែលជាសន្តតិជន ឬ ជាអច្ច័យលាភី ឬ បុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ អាចដឹងពីការភាន់ច្រឡំនោះដែរ។[17] ការភាន់ច្រឡំអាចជាការភាន់ច្រឡំលើចំណុចទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែក ឬ លក្ខណៈនៃសន្តតិជន ឬ អច្ច័យលាភីជាដើម។

**២. ការឆបោក**

ការឆបោក គឺជាទង្វើរបស់សន្តតិជន ឬ អច្ច័យលាភី ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ឬ តតិយជន មានចេតនាទុច្ចរិត ដោយប្រើឧបាយកល បញ្ឆោត ឬ មធ្យោបាយណាមួយ ក្នុងគោលបំណងដើម្បីឱ្យម្ចាស់បណ្តាំបង្ហាញឆន្ទៈតាមដែលខ្លួនចង់បាន។ ដូចនេះការបង្ហាញឆន្ទៈដោយមានការឆបោក គឺជាការបង្ហាញឆន្ទៈមានវិការៈ។ ប៉ុន្តែក្នុងករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ ក្នុងការធ្វើមតកសាសន៍ ដោយសារការឆបោករបស់តតិយជន ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍បាន លុះត្រាតែសន្តតិជន ឬ អច្ច័យលាភី ឬ អ្នកពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ បានដឹង ឬ អាចដឹងពីការឆបោកនោះ។[18]

**៣. ការគម្រាមកំហែង**

ការគម្រាមកំហែង គឺស្ថានភាពមួយ ដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ ដោយសារមានការគម្រាមកំហែងដោយការសំឡុត ការបំភ័យ ពីសំណាក់សន្តតិជន ឬ អច្ច័យលាភី ឬ បុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍តាមរយៈមតកសាសន៍ ឬ តតិយជន។[19] ការគម្រាមកំហែងអាចធ្វើតាមរយៈ ពាក្យសំដី ហិង្សា និងរូបភាពនៃការគម្រាមកំហែងដទៃទៀត ក្នុងគោលបំណងឱ្យម្ចាស់បណ្តាំបង្ហាញឆន្ទៈតាមដែលខ្លួនចង់បាន។

**៤. ព័ត៌មានមិនពិត**

ព័ត៌មានមិនពិត គឺជាស្ថានភាពដោយមានបុគ្គលណាម្នាក់ បានលើកឡើងនូវហេតុណាមួយខុសពីការ

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៦ កថាខណ្ឌទី១, ទី២

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៤៧

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៥០

ពិត ហើយម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈដោយជឿជាក់ថាហេតុនោះជាការពិត។ ប៉ុន្តែប្រសិនម្ចាស់បណ្តាំដែលបង្ហាញឆន្ទៈដោយសារព័ត៌មានមិនពិត ដឹងពីហេតុមិនពិត ក៏ម្ចាស់បណ្តាំមិនបង្ហាញឆន្ទៈដែរ។[20]

### ៥. ការរំលោភបំពានលើស្ថានភាព

ការរំលោភបំពានលើស្ថានភាពមានន័យថា ការធ្វើសកម្មភាពដែលភាគីបានស្ថិតក្នុងស្ថានភាពមួយមិនស្មើគ្នាដែលផ្ទុយពីគោលការណ៍សមភាព។ ការរំលោភបំពានលើស្ថានភាពកើតឡើងនៅពេលធ្វើមតកសាសន៍ ដោយមានបុគ្គលដែលពាក់ពព័ន្ធផលប្រយោជន៍ បានប្រើដោយមិនត្រឹមត្រូវនូវឋានៈដែលមានអាទិភាពជាងម្ចាស់បណ្តាំ ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀត ដែលម្ចាស់បណ្តាំមិនអាចប្រឆាំងតបបាន។[21] ក្នុងករណីដែលមានការរំលោភបំពានលើស្ថានភាព ចាំបាច់ត្រូវតែជាប្រើប្រាស់នូវឋានៈដែលមិនត្រឹមត្រូវ។

## ផ្នែកទី៣៖ ភាពចាំបាច់នៃទម្រង់មតកសាសន៍

មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។[22] តាមន័យនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បាន ដោយខ្លួនត្រូវធ្វើឡើងតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ។ មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ។[23]

មតកសាសន៍ ដែលត្រូវបានធ្វើឡើងតាមទម្រង់ ដែលច្បាប់កំណត់ នឹងត្រូវបង្កើតសុពលភាពនៃទម្រង់ (កថាខណ្ឌទី១) ហើយមតកសាសន៍ដែលបានចុះកាលបរិច្ឆេទ ត្រឹមត្រូវ នឹងបង្កើតសុពលភាពនៃពេលវេលានៃលិខិត (កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់។[24] ដើម្បីបង្ហាញពីឆន្ទៈរបស់ម្ចាស់បណ្តាំឱ្យបានច្បាស់លាស់ ជៀសវាងទំនាស់នៅពេលក្រោយ និងដើម្បីការពារកុំឱ្យមានការក្លែងបន្លំលើលិខិត ទើបក្រមរដ្ឋប្បវេណី បានកំណត់ច្បាស់លាស់ចំពោះទម្រង់នៃមតកសាសន៍។ ក្នុងន័យច្បាប់ យើងអាចធ្វើការកត់សម្គាល់ និងកំណត់អំពីទម្រង់នៃលិខិត

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៤៨

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៤៩

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ កថាខណ្ឌទី១

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧១

មតកសាសន៍ ជាពីរ (០២) ប្រភេទផ្សេងគ្នា គឺមតកសាសន៍តាមទម្រង់ធម្មតា និងមតកសាសន៍តាមទម្រង់ពិសេស។

មតកសាសន៍តាមទម្រង់ធម្មតា សំដៅដល់មតកសាសន៍ដែលធ្វើឡើងដោយបុគ្គលដែលជាម្ចាស់បណ្ដាំ មានសមត្ថភាពពេញលេញ ក្នុងការធ្វើសកម្មភាព អាចវិនិច្ឆ័យដឹងខុសត្រូវ អាចបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួនបាន ដោយមិនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ណាមួយ។ ចំណែកមតកសាសន៍តាមទម្រង់ពិសេស ជាការធ្វើមតកសាសន៍ក្នុងស្ថានភាពពិសេស ដូចជាម្ចាស់បណ្ដាំបាន និងកំពុងជួបគ្រោះថ្នាក់បន្ទាន់ណាមួយដល់អាយុជីវិត ម្ចាស់បណ្ដាំជាបុគ្គលដែលត្រូវបានរឹតត្បិតសេរីភាព ជាបុគ្គលដែលមិនអាចនិយាយ ឬ ស្ដាប់បាន ឬ ស្ថិតក្នុងស្ថានភាពពិសេសណាមួយផ្សេងទៀត ដែលធ្វើឱ្យម្ចាស់បណ្ដាំ មិនអាចធ្វើមតកសាសន៍តាមទម្រង់ធម្មតានោះបាន។ លក្ខខណ្ឌសំខាន់ៗដែលមានកំណត់ចំពោះទម្រង់នៃលិខិតមតកសាសន៍នីមួយៗនឹងត្រូវបកស្រាយលម្អិតនៅក្នុងជំពូកទី២ (មតកសាសន៍តាមទម្រង់ធម្មតា) និងជំពូកទី៣ (មតកសាសន៍តាមទម្រង់ពិសេស)។

**កថាខណ្ឌទី២៖ ការចុះកាលបរិច្ឆេទ**

នៅក្នុងមតកសាសន៍ ចាំបាច់ត្រូវចុះកាលបរិច្ឆេទ នៃការធ្វើមតកសាសន៍ឱ្យបានច្បាស់លាស់ ដើម្បីបញ្ជាក់ពីពេលវេលានៃការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្ដាំ។

មិនមានបញ្ហាទេ ប្រសិនបើម្ចាស់បណ្ដាំបានធ្វើមតកសាសន៍តែម្ដង ឬ មានតែមួយ ប៉ុន្តែបើម្ចាស់បណ្ដាំបានធ្វើមតកសាសន៍ច្រើនដង ដោយបានកែប្រែ ឬ លុបចោលនូវឆន្ទៈផ្នែកណាមួយ ឬ ទាំងមូល និងមិនបានបញ្ជាក់ពីកាលបរិច្ឆេទទេ នោះយើងនឹងមិនអាចបញ្ជាក់ថា មតកសាសន៍ណា ជាការបង្ហាញឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្ដាំឡើយ។

មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នានេះ។[25] ប្រសិនបើ មតកសាសន៍ច្រើនបានធ្វើឡើងដោយពុំបានកំណត់កាលបរិច្ឆេទឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ឬ មតកសាសន៍ដែលបានកំណត់ត្រឹមថ្ងៃ ខែ ខ្វះឆ្នាំ ឬ កំណត់ថ្ងៃ ឆ្នាំ ខ្វះខែ ជាអាទិ៍ មតកសាសន៍នោះ នឹងមានសុពលភាព ប្រសិនបើមតកសាសន៍នោះគ្មានចំណុចផ្ទុយនឹងមតកសាសន៍ផ្សេងទៀត។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ផ្ទុយនឹងគ្នា អានុភាពនៃ

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី២

មតកសាសន៍ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។[26] ម៉្យាងវិញទៀត បើមានមតកសាសន៍ដែលមានថ្ងៃខែឆ្នាំ និងមតកសាសន៍ដែលគ្មានថ្ងៃខែឆ្នាំមានច្រើន មតកសាសន៍ដែលមានថ្ងៃខែឆ្នាំ មានអាទិភាពជាង។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី៣

# ជំពូកទី២៖

# មតកសាសន៍ តាមទម្រង់ធម្មតា

ដូចបានរៀបរាប់នៅជំពូកខាងលើហើយថា មតកសាសន៍ត្រូវបានកំណត់បែងចែកជាពីរប្រភេទផ្សេងគ្នា គឺមតកសាសន៍តាមទម្រង់ធម្មតា និងមតកសាសន៍តាមទម្រង់ពិសេស។ ក្នុងជំពូកនេះ យើងនឹងធ្វើការសិក្សាលើ លិខិតមតកសាសន៍តាមទម្រង់ធម្មតាជាមុន រួមមានជាអាទិ៍ (ផ្នែកទី១)មតកសាសន៍ដោយលិខិតយថាភូត, (ផ្នែកទី២) មតកសាសន៍ដោយលិខិតឯកជន និង (ផ្នែកទី៣) មតកសាសន៍ដោយលិខិតសម្ងាត់។

## ផ្នែកទី១៖ មតកសាសន៍ដោយលិខិតយថាភូត

អត្ថន័យនៃលិខិតយថាភូត ត្រូវបានប្រែប្រួលតាមស្ថានភាព និងកាលៈទេសៈនីមួយៗ ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ចាប់ពីពេលនេះតទៅ ហៅកាត់ថា "ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី"។

លិខិតយថាភូតដែលកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី។[27] ក្នុងន័យនេះ ដើម្បីឱ្យមតកសាសន៍អាចធ្វើឡើងក្រោមទម្រង់ជាលិខិតយថាភូតបាន កាលណាមតកសាសន៍ ត្រូវបានធ្វើឡើងដោយមានការចូលរួម ឬ ការតាក់តែងមតកសាសន៍ដោយសារការី ព្រមទាំងអនុវត្តតាមលក្ខខណ្ឌ និងទម្រង់ដែលកំណត់ដោយច្បាប់ ទើបលិខិតនោះមានសុពលភាពអាចអនុវត្តបាន។ ដើម្បីឱ្យជ្រាបច្បាស់អំពីទម្រង់សំខាន់ៗនៃការតាក់តែង មតកសាសន៍ដោយលិខិតយថាភូត ដែលត្រូវបានកំណត់ដោយច្បាប់ ក្នុងផ្នែកនេះ យើងនឹងបែងចែកជាពីរ កថាខណ្ឌ គឺ (កថាខណ្ឌទី១) ការតាក់តែងមតកសាសន៍ និង (កថាខណ្ឌទី ២) និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍។

### កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍

មតកសាសន៍ដោយលិខិតយថាភូត ជាទម្រង់ដែលមានភាពច្បាស់លាស់ និងពិតប្រាកដ ព្រមទាំងមានលក្ខណៈពិសេសជាងមតកសាសន៍តាមទម្រង់ដទៃទៀត ដោយហេតុថា មតកសាសន៍ប្រភេទនេះត្រូវបានធ្វើឡើងដោយមានការចូលរួមពីសារការី ដែលជាអ្នកដែលផ្តល់យថាភូតភាពលើលិខិត ដែលត្រូវបាន គេជឿជាក់ថា ជាលិខិតដែលធ្វើឡើងត្រឹមត្រូវស្របតាមច្បាប់។ ម្យ៉ាងទៀត វាមានភាពងាយស្រួលសម្រាប់

[27] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ៩ ចំណុច គ

ម្ចាស់បណ្តាំ ទោះបីជាខ្លួនជាអនក្ខជន [28] ក៏អាចធ្វើមតកសាសន៍បានដែរ។ មតកសាសន៍តាមទម្រង់លិខិតយថាភូត ត្រូវបានកំណត់យ៉ាងជាក់លាក់ចំពោះ (១) អ្នកទទួលបន្ទុកក្នុងការតាក់តែង និង (២) ទម្រង់ចាំបាច់នៃលិខិតនេះ។

**១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍**

មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី។ មានតែសារការីទេ ដែលជាអ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ដោយលិខិតយថាភូត។

សារការី (Notary Public/Notaire) ជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូត បញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលតម្រូវឱ្យមានការបញ្ជាក់។[29] សារការី ជាមន្ត្រីសាធារណៈ ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។

ការធ្វើមតកសាសន៍ដោយលិខិតយថាភូត អាចធ្វើនៅទីកន្លែងណាក៏បាន នៅក្នុងប្រទេសកម្ពុជាដែលមានសារការី អាចបញ្ជាក់ និងអាចតាក់តែងបាន។ ដោយឡែក ចំពោះប្រជាជនខ្មែរដែលរស់នៅបរទេសវិញ ការធ្វើមតកសាសន៍ដោយលិខិតយថាភូត អាចធ្វើឡើងដោយកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបានដោយអនុលោមតាមមាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណី។

**២. ទម្រង់ចាំបាច់ នៃមតកសាសន៍**

មតកសាសន៍ដោយលិខិតយថាភូត ត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី ដោយត្រូវធ្វើឡើងតាមទម្រង់ ដែលត្រូវបានកំណត់ដោយច្បាប់ រួមមានជាអាទិ៍៖ (ក) វត្តមានសាក្សី, និង (ខ) ការថ្លែងនូវខ្លឹមសារមតកសាសន៍ និង (គ) ការសរសេរ និងការផ្ទៀងផ្ទាត់ នូវខ្លឹមសារមតកសាសន៍ ។

**ក. វត្តមានសាក្សី**

ទោះបីជាការធ្វើមតសាសន៍ដោយលិខិតយថាភូត ត្រូវបានធ្វើឡើងនៅចំពោះមុខសារការី ដែលជាមន្ត្រីសាធារណៈ ដែលបានផ្តល់ភាពត្រឹមត្រូវ ឬ យថាភូតភាពនៃលិខិតក៏ដោយ ក៏វាជាបញ្ហាដែលចាំបាច់ត្រូវមានការចូលរួម និងមានវត្តមានរបស់សាក្សីយ៉ាងតិច ចំនួន ០២ (ពីរ) នាក់។[30]

សាក្សីនៅក្នុងន័យនេះ ច្បាប់មិនបានកំណត់អំពីកម្រិតវប្បធម៌នៃការយល់ដឹងរបស់សាក្សីឡើយ។ ប៉ុន្តែដោយហេតុថា ក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូត សារការី នឹងសូត្រនូវខ្លឹមសារនៃមតកសាសន៍ជូន

[28] សំដៅដល់ ជនដែលមិនចេះអក្សរ

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ២២, លេខ១៥៤

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច ក

ម្ចាស់បណ្តាំ និងសាក្សីស្តាប់ ដូច្នេះហើយ ប្រសិនបើសាក្សីជាបុគ្គលដែលចេះអានអក្សរ វាជាការប្រសើរក្នុងការផ្ទៀងផ្ទាត់នូវខ្លឹមសារ។

ម៉្យាងវិញទៀត អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើលិខិតបណ្តាំបានឡើយ ព្រោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ សុទ្ធតែជាជនដែលត្រូវបានកម្រិតសមត្ថភាព ក្នុងការធ្វើសកម្មភាព ដូច្នេះ បើឱ្យបុគ្គលនេះ មកធ្វើជាសាក្សីក្នុងការធ្វើមតកសាសន៍ នោះសកម្មភាពរបស់ជនទាំងនេះនឹងមិនមានអានុភាពតាមផ្លូវច្បាប់ឡើយ។

ទន្ទឹមនឹងនេះផងដែរ ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះក៏មិនអាចធ្វើជាសាក្សីបានឡើយ។ ការកំណត់បែបនេះ ក្នុងគោលបំណងដើម្បីការពារការសម្ងាត់របស់ម្ចាស់បណ្តាំក្នុងការចាត់ចែងទ្រព្យសម្បត្តិ ឱ្យទៅជនដែលត្រូវទទួលផលប្រយោជន៍តាមរយៈមតកសាសន៍ ដោយសេរី និងពិតប្រាកដតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

បន្ថែមពីនេះ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ និងនិយោជិត របស់សារការី មិនអាចក្លាយជាសាក្សីក្នុងលិខិតមតកសាសន៍ដោយលិខិតយថាភូតដែរ។

### ខ. ការថ្លែងដោយផ្ទាល់មាត់ នូវខ្លឹមសារមតកសាសន៍

ការតាក់តែងនូវលិខិតមតកសាសន៍ ចាំបាច់ត្រូវគោរពតាមឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ម្ចាស់បណ្តាំ ត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ទៅកាន់សារការី។[31] ម្ចាស់បណ្តាំត្រូវរៀបរាប់ប្រាប់សារការី នូវកម្មវត្ថុនៃការធ្វើមតកសាសន៍ក្នុងការចាត់ចែងនូវទ្រព្យរបស់ខ្លួន ទៅឱ្យសន្តតិជន ឬ ទៅឱ្យអច្ច័យលាភី ដោយធ្វើការកំណត់ឱ្យបានច្បាស់លាស់ នូវការចាត់ចែងនូវទ្រព្យទាំងមូលឬដោយផ្នែក ឬ កំណត់ទ្រព្យជាក់លាក់ណាមួយ។

### គ. ការសរសេរ និងការផ្ទៀងផ្ទាត់នូវមតកសាសន៍

បន្ទាប់ពីស្តាប់ការថ្លែងដោយផ្ទាល់មាត់របស់ម្ចាស់បណ្តាំហើយ សារការី ត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។ [32] ម្ចាស់បណ្តាំ អាចពិនិត្យមើលនូវខ្លឹមសារនៃមតកសាសន៍ ដែលសារការីបានសូត្រ ឬ តាក់តែងនោះត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនពិតប្រាកដដែរឬទេ។ នៅខណៈនោះ ក៏ត្រូវចាំបាច់មានការចូលរួមពីសាក្សីយ៉ាងតិចចំនួន ០២

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច ខ

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច គ

នាក់ ដើម្បីធ្វើឱ្យប្រាកដថា លិខិតមតកសាសន៍ គឺពិតជាត្រូវបានធ្វើឡើងតាមឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។

បន្ទាប់ពីបានពិនិត្យនូវ ខ្លឹមសារនៃមតកសាសន៍ដែលបានធ្វើឡើងដោយលាយលក្ខណ៍អក្សររួច ថាពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ម្ចាស់បណ្ដាំពិតប្រាកដ ម្ចាស់បណ្ដាំ និងសាក្សី ត្រូវធ្វើឱ្យមានភាពច្បាស់លាស់លើឯកសារអំពីឈ្មោះ អាយុ លំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។[33] ក្រោយពីគូភាគី បានចុះហត្ថលេខាបញ្ជាក់ពីភាពត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនរួចមក សារការី ត្រូវសរសេរថ្ងៃខែឆ្នាំ និងចុះហត្ថលេខា លើមតកសាសន៍។[34]

### **កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍**

ទោះបីលិខិតមតកសាសន៍ ត្រូវបានធ្វើឡើងត្រឹមត្រូវតាមឆន្ទៈរបស់ម្ចាស់បណ្ដាំរួចហើយក៏ដោយ ក៏សារការីចាំបាច់ត្រូវចុះនិទ្ទេស (១) អំពីហេតុណាមួយ ប្រសិនបើការធ្វើមតកសាសន៍ត្រូវបានធ្វើឡើងក្នុងស្ថានភាពពិសេសណាមួយដែលមិនអាចបំពេញបាន និងត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ (២)។

#### **១. និទ្ទេសដែលត្រូវចុះ**

ក្រោយពីការតាក់តែងនូវលិខិតមតកសាសន៍ តាមឆន្ទៈរបស់ម្ចាស់បណ្ដាំ ព្រមទាំងបានពិនិត្យ និងស្ដាប់នូវការសូត្រឡើងវិញនូវមតកសាស៍រួច ម្ចាស់បណ្ដាំ ត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវលើលិខិតមតកសាសន៍ នៅចំពោះមុខសារការី។ ទោះបីមិនមានការកំណត់ច្បាស់លាស់អំពីការចុះហត្ថលេខា ប៉ុន្តែម្ចាស់បណ្ដាំ គប្បីចុះហត្ថលេខា នៅរឹមគ្រប់ទំព័រ ប្រសិនបើមតកសាសន៍ធ្វើឡើងដោយមានច្រើនទំព័រ។

ប្រសិនបើម្ចាស់បណ្ដាំមិនអាចសរសេរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខា ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរ បន្ថែមនូវហេតុនោះផង។[35] មានន័យថា សារការីត្រូវសរសេរ ឬ បញ្ជាក់ឱ្យបានច្បាស់លាស់ នូវហេតុដែលម្ចាស់បណ្ដាំមិនអាចសរសេរ ឬ មិនអាចចុះហត្ថលេខាលើមតកសាសន៍បាន។

#### **២. ការរក្សាមតកសាសន៍**

តាមការអនុវត្តជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជា កន្លងមក ការធ្វើមតកសាសន៍ដោយលិខិតយថាភូតត្រូវបានធ្វើឡើងតែមួយ (០១) ច្បាប់ដើម តែប៉ុណ្ណោះ ដែលត្រូវរក្សាទុកជាសម្ងាត់នៅមន្ទីរសារការីដែលម្ចាស់បណ្ដាំបានធ្វើ។ គ្មានបុគ្គលណាមួយ មានសិទ្ធិបើកមតកសាសន៍បានទេ រហូតដល់ពេលដែលម្ចាស់បណ្ដាំបាន

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច ឃ វាក្យខណ្ឌទី១

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច ង

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣ កថាខណ្ឌទី២ ចំណុច ឃ វាក្យខណ្ឌទី២

ទទួលមរណភាព។ ការរក្សាមតកសាសន៍ដោយសារការី មិនមែនជាលក្ខខណ្ឌទម្រង់ដែលបានកំណត់ដោយច្បាប់ឡើយ ប៉ុន្តែក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូត ម្ចាស់បណ្តាំ គប្បីរក្សាទុកមតកសាសន៍នៅសារការី ព្រោះថា សារការី អាចថែរក្សាមតកសាសន៍បានយ៉ាងល្អ និងមានសុវត្ថិភាព។ ការរក្សាទុកដោយម្ចាស់បណ្តាំផ្ទាល់ ឬ តតិយជន អាចធ្វើឱ្យបាត់មតកសាសន៍ ឬ មានការក្លែងបន្លំ ដោយប្រការណាមួយ។

សន្តតិជន ឬ អច្ច័យទាន អាចត្រូវបានទទួលដំណឹងអំពីលិខិតមតកសាសន៍ដែលបានតម្កល់ទុកនូវមន្ទីរសារការី ដោយការជូនដំណឹងរបស់សារការី ឬ សាក្សីដែលបានចូលរួមក្នុងការធ្វើមតកសាសន៍។ សន្តតិជន អាចស្នើសុំបើកនូវមតកសាសន៍នោះបាន កាលបើខ្លួនបានទទួលដំណឹង ព្រមទាំងមានលិខិតបញ្ជាក់ពីអត្តសញ្ញាណឱ្យបានច្បាស់លាស់។ លិខិតមតកសាសន៍ នឹងបង្កើតអានុភាព និងអាចអនុវត្តបានដោយមិនចាំបាច់ឆ្លងកាត់ការបញ្ជាក់ពីតុលាការឡើយ។[36]

## ផ្នែកទី២៖ មតកសាសន៍ដោយលិខិតឯកជន

លិខិតឯកជន សំដៅដល់ លិខិតទាំងឡាយណាដែលបង្កើតឡើងដោយ បុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។[37] មតកសាសន៍ដោយលិខិតឯកជន អាចនិយាយបានថា ជាលិខិតបណ្តាំដែលម្ចាស់បណ្តាំដែលបានធ្វើឡើងដោយឯកឯង ឬ តែម្នាក់ឯងជាលក្ខណៈឯកជន ដោយមិនមានការចូលរួមពីសារការី ឬ បុគ្គលណាមួយនោះទេ។ បើទោះបីជាម្ចាស់បណ្តាំអាចធ្វើឡើងដោយតែឯកឯងក៏ដោយ ក៏ម្ចាស់បណ្តាំចាំបាច់ត្រូវធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់ដោយច្បាប់។

ដូចគ្នាដែរ នៅក្នុងផ្នែកនេះ យើងនឹងបែងចែកជាពីរកថាខណ្ឌ គឺ (កថាខណ្ឌទី១) ការតាក់តែងមតកសាសន៍ និង (កថាខណ្ឌទី២) និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍។

### កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍

ទម្រង់នៃការតាក់តែងនូវលិខិតមតកសាន៍ដោយលិខិតឯកជន ត្រូវបានកំណត់យ៉ាងជាក់លាក់ដោយក្រមរដ្ឋប្បវេណីកម្ពុជា (១) ចំពោះអ្នកទទួលបន្ទុកក្នុងការតាក់តែងនូវមតកសាសន៍នេះ ព្រមទាំង (២) ទម្រង់ចាំបាច់ដែលម្ចាស់បណ្តាំត្រូវអនុវត្តតាម ដើម្បីឱ្យមតកសាសន៍បង្កើតសុពលភាពត្រឹមត្រូវស្របតាមច្បាប់។

#### ១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍

មតកសាសន៍ដោយលិខិតឯកជន ត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំតែម្នាក់ឯងប៉ុណ្ណោះ។ មានន័យ

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៣ កថាខណ្ឌទី២

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ១៩, លេខ ១៣២

ថា មានតែម្ចាស់បណ្តាំម្នាក់គត់ ដែលជាអ្នកតាក់តែងមតកសាសន៍ ដោយគ្មានទេការចូលរួមពីសាក្សី ក៏ដូចជាសារការី។

មតកសាសន៍ដោយលិខិតឯកជនបានផ្តល់ភាពងាយស្រួល និងសារៈប្រយោជន៍ជាច្រើនដល់ម្ចាស់បណ្តាំ ដោយហេតុថា ម្ចាស់បណ្តាំពុំចាំបាច់ស្វែងរកការអន្តរាគមន៍ពីសារការី ឬ សាក្សីដើម្បីចូលរួមនោះឡើយ ម្យ៉ាងទៀត ម្ចាស់បណ្តាំក៏អាចរក្សាខ្លឹមសារនៃមតកសាសន៍ជាការសម្ងាត់ផងដែរ។ ប៉ុន្តែមតកសាសន៍ប្រភេទនេះ ចាំបាច់ទាមទារឱ្យម្ចាស់បណ្តាំជាបុគ្គលដែលមានចំណេះដឹង ចេះសរសេរអក្សរឱ្យបានច្បាស់លាស់។

### ២. ទម្រង់ចាំបាច់ នៃមតកសាសន៍

មតកសាសន៍តាមទម្រង់លិខិតឯកជន ពុំមានភាពស្មុគស្មាញច្រើនដូចទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូតឡើយ។ ទម្រង់ចាំបាច់ទាំងឡាយ ក្នុងការតាក់តែងមតកសាសន៍នេះ គឺ (ក) ការសរសេរនូវមតកសាសន៍ និង (ខ) ការចុះថ្ងៃខែឆ្នាំ និងហត្ថលេខា។

#### ក. ការសរសេរមតកសាសន៍

មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់។[38] ទម្រង់ចាំបាច់ចំពោះការតាក់តែងមតកសាសន៍ដោយលិខិតឯកជន គឺម្ចាស់បណ្តាំចាំបាច់ត្រូវសរសេរនូវខ្លឹមសារ នៃមតកសាសន៍ដោយផ្ទាល់ដៃរបស់ខ្លួន។ បើមតកសាសន៍ដោយលិខិតឯកជន ដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ។[39]

កាលដែលចាំបាច់ត្រូវសរសេរដោយដៃម្ចាស់បណ្តាំផ្ទាល់ ក៏ព្រោះការបង្កើតអានុភាពនូវមកតសាសន៍នឹងត្រូវចាប់ផ្តើម នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព យើងមិនអាចទាមទារឱ្យម្ចាស់បណ្តាំមកធ្វើការបញ្ជាក់ពីចំណុចនីមួយៗបានទេ ប្រសិនបើម្ចាស់បណ្តាំពុំបានសរសេរដោយផ្ទាល់ដៃ នូវខ្លឹមសារឱ្យបានច្បាស់លាស់ ដើម្បីបញ្ជាក់អំពីឆន្ទៈរបស់ខ្លួនទេ។ ម្យ៉ាងវិញទៀត មតកសាសន៍ដោយលិខិតឯកជន មិនមានវត្តមានសាក្សីចូលរួមនោះទេ។

មួយវិញទៀត ក្រោយពេលដែលលិខិតមតកសាន៍ត្រូវបានរកឃើញ ដើម្បីអាចអនុវត្តមតកសាសន៍បាន ចាំបាច់ត្រូវពិនិត្យបញ្ជាក់ដោយតុលាការទៅលើទម្រង់ទាំងឡាយដែលបានកំណត់។ ការពិនិត្យបញ្ជាក់នឹងត្រូវពិនិត្យលើផ្នែក ទម្រង់/អក្សរពិតប្រាកដរបស់ម្ចាស់បណ្តាំ ដោយធ្វើការប្រៀបធៀបនូវការសរសេរនូវ

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២

មតកសាសន៍ ជាមួយនឹងការសរសេរលើឯកសារ ឬ សៀវភៅ ឬ កំណត់ហេតុផ្សេងទៀត ដែលម្ចាស់បណ្តាំធ្លាប់បានសរសេរកន្លងមក។ ដើម្បីឱ្យប្រាកដថា មតកសាសន៍ពិតជាលិខិតដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈចុងក្រោយពិតប្រាកដមែន។

**ខ. ការចុះថ្ងៃខែឆ្នាំ និងហត្ថលេខា**

ក្រោយពេលដែលម្ចាស់បណ្តាំបានសរសេរដោយផ្ទាល់ដៃនូវខ្លឹមសារ នៃមតកសាសន៍រួច ម្ចាស់បណ្តាំត្រូវចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ព្រមទាំងចុះហត្ថលេខាលើលិខិតមតកសាសន៍។ ម្ចាស់បណ្តាំ ត្រូវគោរពតាមទម្រង់ដែលបានកំណត់ឱ្យបានត្រឹមត្រូវ ដើម្បីការពារនូវផលប្រយោជន៍របស់ខ្លួន ព្រមទាំងសន្តតិជន ឬ/និងអច្ច័យលាភី។ ការចុះកាលបរិច្ឆេទ នឹងបញ្ជាក់ពីពេលវេលាដែលម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈក្នុងការបង្កើតមតកសាសន៍ ប្រសិនបើមានមតកសាសន៍ច្រើនត្រូវបានរកឃើញ មតកសាសន៍ដែលមានកាលបរិច្ឆេទចុងក្រោយ នឹងត្រូវបង្កើតអានុភាពតាមផ្លូវច្បាប់។

**កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍**

**១. និទ្ទេសដែលត្រូវចុះ**

ក្រមរដ្ឋប្បវេណី មិនបានកំណត់ជាក់លាក់អំពីទំព័រដែលត្រូវចុះហត្ថលេខាឡើយ ប៉ុន្តែដើម្បីឲ្យមានភាពច្បាស់លាស់នៃមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្តាំ គប្បីចុះហត្ថលេខានៅគ្រប់រឹមទំព័រនៃមតកសាសន៍។ កាលបើមតកសាសន៍ដោយលិខិតឯកជនត្រូវបានការបន្ថែម ឬ កែប្រែ ឬ លុបចោល ឬ ឆូតនៅលើផ្នែកណាមួយ ការបន្ថែម ឬ កែប្រែ ឬ ការលុបចោល ឬ ឆូត ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំ មិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែ ជាពិសេសបើមិនបានចុះហត្ថលេខា។[40] ភាពចាំបាច់នៃការសរសេរបន្ថែមនូវហេតុដែលនាំឱ្យមានការកែប្រែ និងការចុះហត្ថលេខា ដោយហេតុថា យើងមិនអាចដឹងថា ការកែប្រែ ឬ លុបចោលនូវផ្នែកណាមួយ គឺពិតជាឆន្ទៈរបស់ម្ចាស់បណ្តាំឬយ៉ាណានោះទេ។

**២. ការរក្សាមតកសាសន៍**

ដោយហេតុថា មតកសាសន៍ដោយលិខិតឯកជន ត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំដោយឯកឯង នោះម្ចាស់បណ្តាំក៏អាចការរក្សានូវមតកសាសន៍ដោយផ្ទាល់បានដែរ។

ម្ចាស់បណ្តាំក៏អាចរក្សាមតកសាន៍ ដោយដាក់ក្នុងស្រោមសំបុត្របិទជិត ព្រមទាំងចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃ ឬ បោះត្រាលើស្រោមសំបុត្រ។ ទោះបីចំណុចទាំងនេះមិនមែនជាលក្ខខណ្ឌដែលតម្រូវដោយច្បាប់ទេ ប៉ុន្តែម្ចាស់បណ្តាំអាចធ្វើឡើងការពារដើម្បីកុំឱ្យមានការកែប្រែ ឬ ក្លែងបន្លំនូវមតកសាសន៍។

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៤ កថាខណ្ឌទី២

ប្រសិនបើមតកសាសន៍ត្រូវបានរកឃើញ សន្តតិជន ឬ បុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍ ត្រូវដាក់ពាក្យសុំពិនិត្យបញ្ជាក់ទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃមតកសាសន៍។ មតក-សាសន៍ ជាលិខិតឯកជន ផ្តល់ភាពងាយស្រួលដល់ម្ចាស់បណ្តាំក្នុងការតាក់តែង និងអនុញ្ញាតឲ្យម្ចាស់បណ្តាំធ្វើការថែរក្សាដោយខ្លួនឯង ប៉ុន្តែវាបានផ្តល់ការលំបាកក្នុងការស្វែងរកមតកសាសន៍ ព្រោះ សន្តតិជនអាចនឹងពុំបានដឹងថា ម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ឬ មិនដឹងអំពីទីកន្លែងថែរក្សាទុក ក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំ ក្នុងការចាត់ចែងនូវទ្រព្យរបស់ខ្លួន។

## ផ្នែកទី៣៖ មតកសាសន៍ដោយលិខិតសម្ងាត់

ដើម្បីរក្សាខ្លឹមសារមតកសាសន៍ជាសម្ងាត់ ក្រៅពីការធ្វើមតកសាសន៍ជាលិខិតឯកជន ម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ជាលិខិតសម្ងាត់ផងដែរ។ ដើម្បីយល់អំពីមតកសាសន៍ជាលិខិតសម្ងាត់ យើងនឹងបកស្រាយលម្អិតទៅលើទម្រង់នៃការតាក់តែងមតកសាសន៍ដោយលិខិតសម្ងាត់ (កថាខណ្ឌទី១) និងនិទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍ (កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ ការតាក់តែងមតកសាសន៍

ក្នុងការតាក់តែងមតកសាសន៍ដោយលិខិតសម្ងាត់ មិនខុសពីមតកសាសន៍ផ្សេងទៀតទេ ពោលគឺត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវតាមទម្រង់ដែលបានកំណត់ដោយច្បាប់ បើមិនដូច្នេះទេ មតកសាសន៍នោះ នឹងត្រូវចាត់ទុកជាមោឃៈ។ ការតាក់តែងមតកសាសន៍នេះ ត្រូវបានកំណត់ច្បាស់លាស់ចំពោះ (១) អ្នកទទួលបន្ទុកក្នុងការតាក់តែមតកសាសន៍ និង (២) ទម្រង់ចាំបាច់នៃមតកសាសន៍នេះ ។

#### ១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍

ដោយផ្អែកតាមចំណុច គ នៃមាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណី បានចែងថា៖ "ម្ចាស់បណ្តាំ...ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជាមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ"។ តាមអត្ថន័យនេះ មានន័យថាម្ចាស់បណ្តាំអាចសរសេរនូវខ្លឹមសារនៃមតកសាសន៍ដោយខ្លួនឯង ឬ ឱ្យតតិយជនសរសេរជំនួសបាន ដោយផ្ទាល់ដៃក៏បាន សរសេរដោយប្រើម៉ាស៊ីនអង្គុលីលេខ ឬ កុំព្យូទ័រក៏បាន។

ទម្រង់នៃមតកសាសន៍ដោយលិខិតសម្ងាត់ បានបើកសិទ្ធិទូលាយដល់ម្ចាស់បណ្តាំអាចសម្រេចដោយខ្លួនឯងចំពោះការសរសេរមតកសាសន៍ ទោះបីជាម្ចាស់បណ្តាំពុំចេះសរសេរអក្សរ ក៏អាចឱ្យបុគ្គលដទៃសរសេរឱ្យបាន ប៉ុន្តែម្ចាស់បណ្តាំត្រូវគោរពលក្ខខណ្ឌចាំបាច់ផ្សេងទៀតដែលកំណត់ដោយច្បាប់។

### ២. ទម្រង់ចាំបាច់ នៃមតកសាសន៍

ចំពោះមតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើងដោយយោងតាមទម្រង់ដែលកំណត់ដោយក្រមរដ្ឋប្បវេណីរួមមាន៖ (ក) ការសរសេរ និងតាក់តែងនូវមតកសាសន៍ និង (ខ)ការចូលរួមអន្តរាគមន៍របស់សារការី។

#### ក. ការសរសេរ និងតាក់តែងនូវមតកសាសន៍

ក្រោយពីបានឯកភាពលើខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាលើលិខិតមតកសាសន៍។[41] ប្រសិនបើមានការលុប ឬ កែប្រែត្រង់ផ្នែកណាមួយនៃខ្លឹមសារមតកសាសន៍ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខាលើត្រង់ផ្នែកនោះបន្ថែម ទោះបីមិនមែនជាលក្ខខណ្ឌកំណត់ដោយច្បាប់ ប៉ុន្តែការធ្វើបែបនេះ គឺធ្វើឱ្យច្បាស់លាស់ថា ម្ចាស់បណ្តាំ ពិតជាបានបង្ហាញឆន្ទៈកែប្រែ។

ក្រោយពីចុះហត្ថលេខាលើមតកសាសន៍ ម្ចាស់បណ្តាំត្រូវដាក់លិខិតបណ្តាំក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ ឬ មធ្យោបាយផ្សេងទៀត ដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិត នៅមាត់ស្រោមលិខិត។[42]

#### ខ. ការចូលរួមអន្តរាគមន៍របស់សារការី

ម្ចាស់បណ្តាំ ត្រូវដាក់លិខិតដែលបានបិទជិតនៅចំពោះមុខសារការីម្នាក់ និងសាក្សី ២ (ពីរ) នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតដែលដាក់ជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីខ្លួន បានសរសេរ ម្ចាស់បណ្តាំត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។ បន្ទាប់ពីទទួលពីម្ចាស់បណ្តាំ សារការីត្រូវចុះថ្ងៃខែឆ្នាំ ដែលសាមីខ្លួនបានដាក់លិខិត និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាជាមួយនឹងសាក្សី និងម្ចាស់បណ្តាំ។[43]

ចំពោះបុគ្គលដែលអាចក្លាយជាសាក្សីបាន ត្រូវបានកំណត់ដោយច្បាប់ ដូចបានរៀបរាប់នៅក្នុងចំណុច ២ កថាខណ្ឌទី១ ផ្នែកទី១ នៃជំពូកនេះ និងមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណី។

មតកសាសន៍ដោយលិខិតសម្ងាត់ មិនមែន តាក់តែងដោយសារការីទេ សារការីត្រឹមតែអាចរក្សាទុកនូវលិខិតមតកសាសន៍តែប៉ុណ្ណោះ។ មតកសាសន៍ដោយលិខិតសម្ងាត់ បានបើកឱកាសឱ្យបុគ្គលដែលចេះអក្សរអាចសរសេរនូវមតកសាសន៍ ដោយរក្សានូវការសម្ងាត់នៃឆន្ទៈរបស់ខ្លួន ហើយអាចរក្សាទុកនូវមតកសាសន៍

---

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៥ ចំណុច ក

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៥ ចំណុច ខ

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៥ ចំណុច គ និង ឃ

ដោយសារការី ដែលអាចផ្តល់សុវត្ថិភាពដល់លិខិត ហើយមិនមានអ្នកណាមានសិទ្ធិបើកមើល ឬ កែប្រែនូវមតកសាសន៍នេះបានឡើយ។

### កថាខណ្ឌទី២៖ និទ្ទេសដែលត្រូវចុះ និងការរក្សាមតកសាសន៍

#### ១. និទ្ទេសដែលត្រូវចុះ

និទ្ទេសដែលត្រូវចុះក្នុងមតកសាសន៍ គឺ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទ។ ប្រសិនបើមតកសាសន៍មានច្រើនទំព័រ ម្ចាស់បណ្តាំគប្បីចុះហត្ថលេខានៅគ្រប់រឹមទំព័រ ហើយបើមានការកែប្រែ ឬផ្លាស់ប្តូរនូវខ្លឹមសារនៅផ្នែកណាមួយ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខានៅផ្នែកនោះផងដែរ។ ម្ចាស់បណ្តាំ ត្រូវចុះហត្ថលេខា ឬសញ្ញាសម្គាល់ លើស្រោមសំបុត្រដែលដាក់មតកសាសន៍បិទជិត ឱ្យបានច្បាស់លាស់ដើម្បីសម្គាល់ថាមតកសាសន៍មិនទាន់បានបើក។

ចំពោះសារការីវិញ ត្រូវចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខា លើស្រោមសំបុត្រដែលម្ចាស់បណ្តាំបានដាក់។ សារការី ត្រូវសរសេរនូវសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំចំពោះការសរសេរមតកសាសន៍ ថាម្ចាស់បណ្តាំជាអ្នកសរសេរមតកសាសន៍ ដោយម្ចាស់បណ្តាំផ្ទាល់ ឬ ដោយតតិយជន ជាអ្នកសរសេរជំនួស។

ដូចគ្នាផងដែរ សាក្សីដែលមានវត្តមាន ក៏ត្រូវចុះហតហ្ថលេខាលើលិខិតបិទជិតផងដែរ។ ការចុះហត្ថលេខារបស់សាក្សី និងសារការី អាចត្រូវបានជំនួសដោយសរសេរនូវនាមត្រកូល និងនាមខ្លួន និងផ្តិតស្នាមមេដៃ។[44]

#### ២. ការរក្សាមតកសាសន៍

មិនមានការកំណត់រិតត្បិតចំពោះការរក្សាមតកសាសន៍ដោយលិខិតសម្ងាត់ទេ ម្ចាស់បណ្តាំអាចរក្សាមតកសាសន៍ដោយខ្លួនឯង ឬ តតិយជន ឬសារការីក៏បាន។ តាមការអនុវត្តជាក់ស្តែង មតកសាសន៍ ត្រូវបានប្រគល់ឱ្យសារការី ជាអ្នកថែរក្សា ព្រោះការរក្សាមតកសាស៍នៅសារការី គឺមានសុវត្ថិភាព និងមានភាពជឿជាក់ជាង ដែលមានលក្ខណៈដូចគ្នានឹងមតកសាសន៍ដោយលិខិតយថាភូតដែរ។ ទោះបីជា មតកសាសន៍ ត្រូវបានរក្សាទុកដោយអ្នកណាក៏ដោយ ប៉ុន្តែម្ចាស់បណ្តាំត្រូវគោរពតាមទម្រង់ដែលច្បាប់បានកំណត់ ទើបបង្កើតសុពលភាពនៃទម្រង់។ ការរក្សាទុកមតកសាសន៍នេះដោយឯកឯង ដែលមិនត្រូវបានបំពេញតាមទម្រង់នៃមតកសាសន៍ដោយលិខិតសម្ងាត់ទេ មតកសាសន៍អាចមានសុពលភាពលើទម្រង់នៃមតកសាសន៍ដោយលិខិតឯកជនទៅវិញ ប្រសិនបើទម្រង់នៃមតកសាសន៍ដោយលិខិតឯកជន ត្រូវបានបំពេញ។

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨០

# ជំពូកទី៣៖

# មតកសាសន៍ តាមទម្រង់ពិសេស

មតកសាសន៍តាមទម្រង់ពិសេស គឺជាផ្នែកមួយនៃទម្រង់មតកសាសន៍ ដែលកំណត់ដោយក្រមរដ្ឋប្បវេណី។ ការធ្វើមតកសាសន៍ តាមទម្រង់ពិសេស ត្រូវបានយកមកអនុវត្តនៅពេលដែលម្ចាស់បណ្តាំបាន និងកំពុងជួបក្នុងស្ថានភាពពិសេសណាមួយ ដែលធ្វើឱ្យម្ចាស់បណ្តាំមិនអាចធ្វើមតកសាសន៍តាមទម្រង់ធម្មតា។ នៅក្នុងជំពូកនេះ យើងនឹងបែងចែកជាបី (០៣) ផ្នែក រួមមានជាអាទិ៍ (ផ្នែកទី១) មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត, (ផ្នែកទី២) មតកសាសនៃជនដែលត្រូវជាប់ឃុំឃាំង និងនៅក្នុងនាវា ឬយន្តហោះ និង (ផ្នែកទី៣) មតកសាសន៍ ក្នុងស្ថានភាពពិសេសផ្សេងទៀត។

## ផ្នែកទី១៖ មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

ក្នុងករណី ម្ចាស់បណ្តាំត្រូវបាន និងកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ណាមួយដោយមូលហេតុជម្ងឺ ឬ ហេតុផ្សេងទៀត ដែលនាំឱ្យមានបញ្ហាដល់អាយុជីវិតបុគ្គល ហើយម្ចាស់បណ្តាំមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ឬ មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើលិខិតមតកសាសន៍ដោយលិខិតយថាភូតឬមតកសាសន៍ដោយលិខិតសម្ងាត់បានទេ ម្ចាស់បណ្តាំ ដែលកំពុងជួបស្ថានភាពបែបនេះ អាចធ្វើមតកសាសន៍តាមទម្រង់ពិសេសផ្សេងបាន ដោយត្រូវបំពេញតាមទម្រង់ដែលកំណត់ដោយច្បាប់ រួមមាន (កថាខណ្ឌទី១) ទម្រង់នៃការតាក់តែងមតកសាសន៍ និង (កថាខណ្ឌទី២) លក្ខខណ្ឌអានុភាពនៃទម្រង់។

### កថាខណ្ឌទី១៖ ទម្រង់នៃការតាក់តែងមតកសាសន៍

#### ១. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍

អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ក្នុងករណីដែលម្ចាស់បណ្តាំ កំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ដោយហេតុណាមួយក៏ដោយ អ្នកដែលទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍នេះគឺ ជាជនដែលកំពុងមានវត្តមាននៅពេលនោះ។ ទម្រង់ពិសេសក្នុងការតាក់តែងមតកសាសន៍ដែលស្ថិតក្នុងស្ថានភាព តាមការកំណត់ដោយច្បាប់ គឺតម្រូវឱ្យមានវត្តមានរបស់សាក្សី ចំនួន ០៣ (បី) នាក់ ដោយនៅក្នុងចំណោម នោះ គឺមានសាក្សីម្នាក់ដែលជាអ្នកសរសេរ/តាក់តែង នូវខ្លឹមសារនៃមតកសាសន៍ដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈចុងក្រោយរបស់ខ្លួន។ សាក្សីដែលបានចូលរួមនៅពេលធ្វើមតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ត្រូវតែជាជនដែលមានលក្ខណៈសម្បត្តិក្លាយជាសាក្សី តាមបញ្ញត្តិមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណី។

**២. ទម្រង់ចាំបាច់នៃមតកសាសន៍**

ម្ចាស់បណ្ដាំ ត្រូវប្រកាសនូវខ្លឹមសារនៃមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីទាំងបី (០៣) នាក់។ សាក្សីម្នាក់ដែលត្រូវបានទទួលការប្រកាសដោយផ្ទាល់មាត់ នូវខ្លឹមសារនៃមតក-សាសន៍ និងជាអ្នកដែលទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីពីរនាក់ផ្សេងទៀត ស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីទាំងពីរ (០២) នាក់ បានពិនិត្យមើល និងបានទទួលស្គាល់ថាការសរសេរមតកសាសន៍នោះ ត្រឹមត្រូវតាមខ្លឹមសារនៃឆន្ទៈរបស់ម្ចាស់បណ្ដាំរួច សាក្សីទាំងបី (០៣) នាក់ ត្រូវចុះហត្ថលេខាលើលិខិតមតកសាសន៍។[45] សាក្សី គប្បីចុះហត្ថលេខា នៅគ្រប់ទំព័រនៃលិខិតមតកសាសន៍ កាលបើមតកសាសន៍បានធ្វើឡើងដោយមានច្រើនទំព័រ។ សាក្សីនៅក្នុងការធ្វើបណ្ដាំនេះ គឺពិតជាសំខាន់ ព្រោះសាក្សីមិនត្រឹមតែជាអ្នកដឹងលឺនោះទេ ប៉ុន្តែជាអ្នកសរសេរនូវខ្លឹមសារនៃ មតកសាសន៍តែម្តង ដូច្នេះ សាក្សីក្នុងការធ្វើមតកសាសន៍ គប្បីជាជនដែលចេះស្តាប់ និងចេះសរសេរអក្សរ។

ក្បិតកាលបរិច្ឆេទ មិនមែនជាលក្ខខណ្ឌទម្រង់ដើម្បីបង្កើតសុពលភាពមតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ ប៉ុន្តែសាក្សីគួរសរសេរបញ្ជាក់បន្ថែម ចំពោះកាលបរិច្ឆេទដែលខ្លួនបានសរសេរលិខិតមតកសាន៍។ លើសពីនេះទៀត លក្ខខណ្ឌទម្រង់ក៏មិនបានតម្រូវឱ្យមានហត្ថលេខារបស់ម្ចាស់បណ្តាំនោះទេ និងមិនបានកំណត់អំពីវិធីសរសេរនោះដែរ សាក្សីអាចសរសេរដោយផ្ទាល់ដៃ ឬ ដោយប្រើកុំព្យូទ័រ។ បើទោះបីជា លក្ខខណ្ឌទម្រង់ដែលត្រូវបានកំណត់នៅក្នុងកថាខណ្ឌនេះ ត្រូវបានធ្វើឡើងក៏ដោយ ប៉ុន្តែមតកសាសន៍នេះនឹងមិនមានអានុភាពឡើយ ប្រសិនបើលក្ខខណ្ឌអានុភាពនៃទម្រង់ មិនត្រូវបានអនុវត្ត។

**កថាខណ្ឌទី២៖ លក្ខខណ្ឌអានុភាពនៃទម្រង់**

មតកសាសន៍ដែលត្រូវបានធ្វើឡើងតាមទម្រង់ដូចបានរៀបរាប់ខាងលើ នឹងមិនមានអនុភាពឡើយប្រសិនបើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ។[46] ការដាក់ពាក្យសុំ ដើម្បីពិនិត្យ និងបញ្ជាក់មតកសាសន៍ ជាលក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃទម្រង់មតក-សាសន៍ ដោយជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត។ ទោះបីម្ចាស់បណ្តាំ និងសាក្សីដែលបានចូលរួមតាក់តែងមតកសាសន៍ត្រឹមត្រូវតាមទម្រង់ក៏ដោយ សាក្សី ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៧ កថាខណ្ឌទី១

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៧ កថាខណ្ឌទី២

ត្រូវយកមតកសាសន៍នេះ ទៅបញ្ជាក់ត្រឹមត្រូវពីតុលាការដែលមានសមត្ថកិច្ច ដោយការដាក់ពាក្យសុំ ហើយតុលាការនឹងពិចារណា និងវិនិច្ឆ័យលើលិខិតនេះ។ ការវិនិច្ឆ័យសេចក្ដី និងការសម្រេច ជាឆន្ទានុសិទ្ធិរបស់តុលាការ ដោយផ្អែកលើភស្តុតាងដែលផ្ដល់ឱ្យតុលាការអាចជឿជាក់បាន។ តុលាការនឹងមិនអាចបញ្ជាក់មតក-សាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។[47]

## ផ្នែកទី២៖ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង និងនៅក្នុងនាវា ឬយន្តហោះ

ផ្នែកនេះ ជាការកំណត់អំពីទម្រង់នៃមតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង និងនៅក្នុងនាវា ឬយន្តហោះ។ គ្រប់បុគ្គល សុទ្ធតែអាចធ្វើមតកសាសន៍បាន ទោះបីខ្លួនកំពុងស្ថិតនៅក្នុងស្ថានភាពជាប់ឃុំឃាំង នៅក្នុងនាវា ឬនៅក្នុងយន្តហោះ ក៏ដោយ ប៉ុន្តែត្រូវគោរពតាមទម្រង់ដែលកំណត់ដោយច្បាប់។ ទម្រង់នៃការតាក់តែងមតកសាសន៍ក្នុងស្ថានភាពនីមួយៗមានលក្ខណៈខុសពីគ្នា ចំពោះ (កថាខណ្ឌទី១) មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង និង (កថាខណ្ឌទី២) មតកសាសន៍នៃជនដែលនៅក្នុងនាវា ឬយន្តហោះ។

### កថាខណ្ឌទី១៖ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង

ជនដែលត្រូវបានជាប់ឃុំឃាំងក្នុងន័យនេះ សំដៅលើជនដែលត្រូវបានជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬសាលដីកា។ ក្រៅពីមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍តាមទម្រង់ពិសេសមួយផ្សេងទៀត ដែលកំណត់ចំពោះជនដែលត្រូវបានជាប់ឃុំឃាំងបាន។

#### ១. ទម្រង់នៃការតាក់តែងមតកសាសន៍

##### ក. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍

ជនដែលត្រូវបានជាប់ឃុំឃាំង ហើយមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ដោយហេតុមិនចេះអក្សរ របួសស្នាម ឬ ពិការភាព ជាដើម ដែលធ្វើឱ្យម្ចាស់បណ្ដាំមានការលំបាកខ្លាំងក្នុងការធ្វើមតកសាសន៍ដោយខ្លួនឯង អ្នកដែលទទួលបន្ទុកក្នុងការជួយម្ចាស់បណ្ដាំធ្វើមតកសាសន៍ គឺនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងនោះ។ មានតែនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងដែលមានសិទ្ធិតាក់តែងមតកសាសន៍ឱ្យជនដែលជាប់ឃុំឃាំងបាន ដោយអនុលោមតាមទម្រង់ដែលកំណត់ដោយច្បាប់។

##### ខ. ទម្រង់ចាំបាច់នៃមតកសាសន៍

ទម្រង់នៃមតកសាសន៍នៃជនដែលជាប់ឃុំឃាំង មានលក្ខណៈស្រដៀងគ្នានឹងទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូតដែរ ដោយហេតុថា បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី២ នៃមាត្រា ១១៧៣

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៧ កថាខណ្ឌទី៣

(មតកសាសន៍ដោយលិខិតយថាភូត)នៃក្រមរដ្ឋប្បវេណី ត្រូវបានយកមកអនុវត្តដូចគ្នាចំពោះការធ្វើមតក-សាសន៍ នៃជនដែលជាប់ឃុំឃាំង។

ទោះបីជាទម្រង់នៃការតាក់តែងមតកសាសន៍នៃជនដែលត្រូវបានជាប់ឃុំ អនុវត្តតាមបញ្ញត្តិដែលពាក់ព័ន្ធនឹងមតកសាសន៍ដោយលិខិតយថាភូតក្តី ប៉ុន្តែក្នុងន័យនេះ មិនមែនមានន័យថា ជាមតកសាសន៍ដោយលិខិតយថាភូតឡើយ។ នេះគឺគ្រាន់តែ ជាការកំណត់លើទម្រង់ក្នុងការតាក់តែងមតកសាសន៍តែប៉ុណ្ណោះ។ សារការីនៅក្នុងមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណី ត្រូវបានបកស្រាយថាជានគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង។ ប៉ុន្តែនគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំង មិនមែនជាសារការីនោះទេ។

ជារួម មតកសាសន៍នៃជនដែលជាប់ឃុំឃាំង អាចធ្វើឡើងបានដោយ ត្រូវមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ចំនួន ០២ (ពីរ) នាក់។[48] ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ ចំពោះនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង។ នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង ត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សី បានទទួលស្គាល់ថា លិខិតជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ម្ចាស់បណ្តាំ និងសាក្សី ពិនិត្យមើលឱ្យច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខា លើលិខិតមតកសាន៍។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំង អាចជំនួសការសរសេរ និងហត្ថលេខា ដោយការសរសេរឈ្មោះ អាយុ និងលំនៅឋាន របស់ម្ចាស់បណ្តាំ ហើយ នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង ត្រូវសរសេរបន្ថែម នូវហេតុដែលម្ចាស់បណ្តាំមិនចេះចុះហត្ថលេខាផង។ បន្ទាប់មក នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង ត្រូវសរសេរថ្ងៃខែឆ្នាំ និងចុះហត្ថលេខា។

### ២. លក្ខខណ្ឌអានុភាពនៃទម្រង់

ប្រសិនបើ មតកសាសន៍នៃជនដែលត្រូវបានជាប់ឃុំឃាំង ត្រូវបានធ្វើឡើងក្រោមទម្រង់នៃមតក-សាសន៍ដោយលិខិតឯកជន នោះនឹងមិនមានបញ្ហាចោទទេ មតកសាសន៍នេះ នឹងបន្តសុពលភាពរហូត ម្ចាស់បណ្តាំអាចកែប្រែ ឬលុបចោលនូវមតកសាសន៍នេះដោយខ្លួនឯងបាន។ ប៉ុន្តែក្នុងករណីដែល មតកសាសន៍នៃជនដែលត្រូវបានជាប់ឃុំឃាំង ត្រូវបានធ្វើឡើងក្រោមទម្រង់ដូចបានកំណត់ក្នុងចំណុច១ នៃកថាខណ្ឌនេះ មតកសាសន៍ពុំមានអានុភាពឡើយ ប្រសិនបើម្ចាស់បណ្តាំ បន្តនៅរស់ ក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិត

[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ កថាខណ្ឌទី១

ចាប់ពីពេលដែលម្ចាស់បណ្តាំ បែរជាអាចធ្វើមតកសាសន៍បានតាមទម្រង់ធម្មតា ក្រោយពេលដែលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង។[49]

មតកសាសន៍នៃជនដែលត្រូវបានជាប់ឃុំឃាំង ជាមតកសាសន៍ជាបណ្តោះអាសន្នតែប៉ុណ្ណោះ ហេតុនេះប្រសិនបើម្ចាស់បណ្តាំ ត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ម្ចាស់បណ្តាំអាចបង្ហាញឆន្ទៈផ្សេងដោយមតកសាន៍តាមទម្រង់ធម្មតា។ មតកសាសន៍ដែលម្ចាស់បណ្តាំបានធ្វើឡើងនៅពេលកំពុងជាប់ឃុំឃាំង នឹងត្រូវបន្តអានុភាពត្រឹមរយៈពេល ០៦ (ប្រាំមួយ) ខែតែប៉ុណ្ណោះ ដោយគិតចាប់ពីពេលដែលម្ចាស់បណ្តាំ ត្រូវបានដោះលែងពីមន្ទីរឃុំឃាំង។

**កថាខណ្ឌទី២៖ ជនដែលនៅក្នុងនាវា ឬយន្តហោះ**

ចំពោះជនដែលនៅក្នុងនាវា ឬយន្តហោះ ក៏អាចធ្វើមតកសាសន៍បានដែរ តាមទម្រង់ដែលបានកំណត់ដោយច្បាប់។ ទម្រង់នៃមតកសាសន៍នៃជនដែលនៅក្នុងនាវា ឬយន្តហោះ គឺស្រដៀងគ្នានឹងមតកសាសន៍នៃជនដែលត្រូវបានជាប់ឃុំឃាំងដែរ។

**១. ទម្រង់នៃការតាក់តែងមតកសាសន៍**

**ក. អ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍**

ករណីម្ចាស់បណ្តាំនៅក្នុងនាវា អាចធ្វើមតកសាសន៍បាន ដោយត្រូវមានវត្តមានរបស់ មេបញ្ជាការបរិបាលនាវា ឬ បុគ្គលិកនាវាម្នាក់ និងសាក្សីចំនួនពីរ (០២) នាក់ ចំណែកម្ចាស់បណ្តាំនៅក្នុងយន្តហោះ អាចធ្វើមតកសាន៍បាន ដោយមានវត្តមាន មេបញ្ជាការ បរិបាលយន្តហោះ ឬ បុគ្គលិកយន្តហោះម្នាក់ និងសាក្សីចំនួន ០២ នាក់ដែរ។[50] មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬ បុគ្គលិកនាវា ឬយន្តហោះ ជាជនដែលត្រូវទទួលបន្ទុកក្នុងការសរសេរ ឬតាក់តែងមតកសាសន៍ឱ្យម្ចាស់បណ្តាំ នៅក្នុងស្ថានភាពដែលម្ចាស់បណ្តាំ នៅក្នុងនាវា ឬ យន្តហោះ។ អ្នកទទួលបន្ទុកសរសេរមតកសាសន៍ ត្រូវអនុវត្តតាមទម្រង់ដែលកំណត់ដោយច្បាប់។

**ខ. ទម្រង់ចាំបាច់នៃមតកសាសន៍**

បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី២ ចំណុច ខ រហូតដល់ចំណុច ង នៃមាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីស្តីពីមតកសាសន៍ដោយលិខិតយថាភូត ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការធ្វើមតកសាសន៍នៃជននៅក្នុងនាវា ឬយន្តហោះ។ ហើយពាក្យថា សារការី នឹងត្រូវបកស្រាយជាមេបញ្ជាការបរិបាលនាវា ឬយន្តហោះ ឬ បុគ្គលិកនាវា ឬយន្តហោះ។[51]

---

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ កថាខណ្ឌទី៥

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ កថាខណ្ឌទី២

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ កថាខណ្ឌទី៤

ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ដែលមានវត្តមាននៅពេលធ្វើមតកសាសន៍។ មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬ បុគ្គលិកនាវា ឬយន្តហោះ ត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំ ជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ ត្រឹមត្រូវតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។ មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬ បុគ្គលិកនាវា ឬយន្តហោះ ដែលបានសរសេរខ្លឹមសារនៃមតកសាសន៍ ត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីដែលមានវត្តមានស្តាប់។

បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សី បានទទួលស្គាល់ថា ខ្លឹមសារដែលបានសរសេរជាលាយលក្ខណ៍អក្សរ ត្រឹមត្រូវហើយ ម្ចាស់បណ្តាំ និងសាក្សី ត្រូវពិនិត្យឱ្យបានច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន និងត្រូវចុះហត្ថលេខា។ ការចុះហត្ថលេខា គប្បីចុះនៅគ្រប់ទំព័រមតកសាសន៍ ដើម្បីជៀសវាង ក៏លួចផ្លាស់ប្តូរ ឬ កែប្រែគ្រង់ផ្នែក ឬ ទំព័រណាមួយ។ បន្ទាប់មកទៀត មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ត្រូវសរសេរថ្ងៃខែឆ្នាំ និងត្រូវចុះហត្ថលេខា។

**២. លក្ខខណ្ឌអានុភាពនៃទម្រង់**

មតកសាសន៍នៃជនដែលនៅក្នុងនាវា ឬយន្តហោះ មានអានុភាពត្រឹមរយៈពេល ០៦ (ប្រាំមួយ) ខែប៉ុណ្ណោះ គិតចាប់ពីថ្ងៃដែលម្ចាស់បណ្តាំ បែរជាអាចធ្វើមតកសាសន៍ បានតាមទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន ឬ មតកសាសន៍ដោយលិខិតសម្ងាត់ ក្រោយពេលដែលម្ចាស់បណ្តាំត្រូវបានចុះពីនាវា ឬ យន្តហោះ។[52] ក្រោយការចុះពីនាវា ឬ យន្តហោះ ម្ចាស់បណ្តាំ អាចធ្វើមតកសាសន៍តាមទម្រង់ធម្មតាវិញបាន ព្រមទាំងអាចបង្ហាញឆន្ទៈលុបចោលមតកសាសន៍ដែលម្ចាស់បណ្តាំស្ថិតនៅក្នុងនាវា ឬ យន្តហោះបាន។

## ផ្នែកទី៣៖ មតកសាសន៍ ក្នុងស្ថានភាពពិសេសផ្សេងទៀត

ករណីពិសេសផ្សេងទៀត ដែលម្ចាស់បណ្តាំមិនអាចធ្វើមតកសាសន៍តាមទម្រង់ធម្មតា មានដូចជាម្ចាស់បណ្តាំស្ថិតក្នុងស្ថានភាពដែលមិនអាចវិនិច្ឆ័យបាន ឬ ជនដែលមិនអាចនិយាយបាន ឬ ម្ចាស់បណ្តាំមិនមានលំនៅឋាននៅក្នុងស្រុក (មានលំនៅឋាននៅបរទេស) ហើយម្ចាស់បណ្តាំមានបំណងធ្វើមតកសាសន៍។ ទោះបីជាម្ចាស់បណ្តាំស្ថិតក្នុងស្ថានភាពពិសេសណាក៏ដោយ ម្ចាស់បណ្តាំពិតជាអាចធ្វើមតកសាសន៍បានដោយអនុលោមតាមទម្រង់ដែលបានកំណត់ជាក់លាក់ទៅតាមស្ថានភាពនីមួយៗ។ នៅក្នុងផ្នែកនេះ យើងនឹងលើកយកនូវបញ្ញត្តិដែលពាក់ព័ន្ធនឹង (កថាខណ្ឌទី១) មតកសាសន៍នៃជនដែលស្ថិតនៅក្រោមអាណា

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ កថាខណ្ឌទី៥

ព្យាបាលទូទៅ, (កថាខណ្ឌទី២) មតកសាសន៍នៃជនដែលមិនអាចនិយាយបាន និង (កថាខណ្ឌទី៣) មតកសាសន៍ ជនជាតិខ្មែររស់នៅបរទេស មកធ្វើការបកស្រាយ។

**កថាខណ្ឌទី១៖ មតកសាសន៍នៃជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ**

ចំពោះជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[53] ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។[54] តាមអត្ថន័យនេះ ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពបានទេ ទោះបីជាសកម្មភាពឯកតោភាគី ឬ កិច្ចសន្យា។ រាល់ការធ្វើសកម្មភាព ត្រូវធ្វើឡើងដោយមានការយល់ព្រមពី អ្នកអាណាព្យាបាលទូទៅ បើមិនដូច្នេះទេ សកម្មភាពដែលបានធ្វើអាចលុបចោលបាន។

ប៉ុន្តែចំពោះការធ្វើមតកសាសន៍វិញ ច្បាប់បានបញ្ញត្តិពិសេស សម្រាប់ម្ចាស់បណ្តាំជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បានមិនចាំបាច់មានការអនុញ្ញាតិពីអ្នកអាណា-ព្យាបាលទូទៅឡើយ លុះត្រាតែ (១) ម្ចាស់បណ្តាំបានជាសះស្បើយពីជម្ងឺក្នុងកម្រិតណាមួយ និង (២) វត្តមានវេជ្ជបណ្ឌិត។

**១. លក្ខខណ្ឌសះស្បើយពីជម្ងឺ**

មតកសាសន៍នៃជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន ព្រមទាំងមានសុពលភាព លុះត្រាតែជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ម្ចាស់បណ្តាំ ដែលបានធ្វើ។ ការជាសះស្បើយ សំដៅដល់ស្ថានភាពដែលម្ចាស់បណ្តាំមានស្មារតី ដឹងខុសត្រូវ ដឹងច្បាស់ពីអំពើដែលម្ចាស់បណ្តាំធ្វើ ម្ចាស់បណ្តាំអាចវិនិច្ឆ័យសេចក្តី និងអាចដឹងពីលទ្ធផលនៃអំពើរបស់ម្ចាស់បណ្តាំតាមផ្លូវច្បាប់បាន ទោះបីជាមិនទាន់បានទទួលការប្រកាសរបស់តុលាការអំពី ការសម្រេចលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅក៏ដោយ។ ប៉ុន្តែស្ថានភាពដែលអាចកំណត់ថា ម្ចាស់បណ្តាំ អាចដឹង និងវិនិច្ឆ័យបាន ក្នុងកម្រិតណាមួយបានជាការវិនិច្ឆ័យរបស់វេជ្ជបណ្ឌិតដែលមានជំនាញ។

---

[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២៤ កថាខណ្ឌទី១

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦

**២. វត្តមានវេជ្ជបណ្ឌិត**

វេជ្ជបណ្ឌិតយ៉ាងតិចពីរ (០២) នាក់ត្រូវមានវត្តមាន នៅពេលម្ចាស់បណ្តាំធ្វើមតកសាសន៍។[55] វេជ្ជបណ្ឌិត ត្រូវវាយតម្លៃ និងពិនិត្យឱ្យបានច្បាស់លាស់លើស្ថានភាពជាក់ស្តែងរបស់ម្ចាស់បណ្តាំ ព្រោះថាមតកសាសន៍នៃជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ វេជ្ជបណ្ឌិតត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍ថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ម្ចាស់បណ្តាំ ដោយសារមានវិបត្តិស្មារតីទេ។ បន្ថែមពីនេះ វេជ្ជបណ្ឌិត ត្រូវចុះហត្ថលេខាលើមតកសាសន៍ផងដែរ។[56] វត្តមានរបស់វេជ្ជបណ្ឌិត គឺពិតជាសំខាន់ណាស់ ក្នុងការបញ្ជាក់ថា ម្ចាស់បណ្តាំ មិនបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៅពេលម្ចាស់បណ្តាំធ្វើមតកសាសន៍។

សូមបញ្ជាក់ផងដែរថា លក្ខខណ្ឌសុពលភាពនៃទម្រង់ ដែលកំណត់ខាងលើនេះ ជាទម្រង់បន្ថែមទៅលើទម្រង់នៃមតកសាសន៍នីមួយៗ ម្ចាស់បណ្តាំ មានជម្រើសក្នុងការជ្រើសរើសទម្រង់នៃមតកសាសន៍ណាមួយ តាមឆន្ទៈរបស់ខ្លួន។

**កថាខណ្ឌទី២៖ មតកសាសន៍នៃជនដែលមិនអាចនិយាយបាន ឬមិនអាចស្តាប់បាន**

បើម្ចាស់បណ្តាំ បានស្ថិតនៅក្នុងស្ថានភាពដែលមិនអាចនិយាយបាន ឬ មិនអាចស្តាប់បាន ដោយមូលហេតុនៃជម្ងឺ ឬ មូលហេតុផ្សេងទៀត ប៉ុន្តែម្ចាស់បណ្តាំមានបំណងធ្វើមតកសាសន៍ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ បានដោយត្រូវបំពេញលក្ខខណ្ឌទម្រង់មួយចំនួនបន្ថែមទៀតដែលច្បាប់បានបញ្ញត្តិពិសេសចំពោះហេតុនីមួយៗ (១) ចំពោះម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន និង (២) ចំពោះម្ចាស់បណ្តាំ និងសាក្សី ជាជនដែលមិនអាចស្តាប់បាន។

**១. ម្ចាស់បណ្តាំជាជនដែលមិនអាចនិយាយបាន**

នៅក្នុងករណីដែលបុគ្គលដែលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូតមតកសាសន៍ដោយលិខិតសម្ងាត់ និងមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ជាដើម ម្ចាស់បណ្តាំ អាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថា លិខិតដែលបានដាក់ស្រោមសំបុត្របិទជិតជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី។[57]

[55] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៦ កថាខណ្ឌទី១

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៦ កថាខណ្ឌទី២

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាណ្ឌទី១

នេះជាករណីពិសេស ក្នុងករណីម្ចាស់បណ្តាំ ជាបុគ្គលដែលមិនអាចនិយាយបាន ហើយម្ចាស់បណ្តាំត្រូវបង្ហាញឆន្ទៈធ្វើមតកសាសន៍បាន ដោយជំនួសការការថ្លែងដោយផ្ទាល់មាត់ ដោយការបកប្រែរបស់អ្នកបកប្រែ។

ម៉្យាងវិញទៀត ប្រសិនបើមានហេតុដូចនេះបានកើតឡើង សារការីដែលជាអ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍ដោយលិខិតយថាភូត និងជាអ្នកទទួលបន្ទុកក្នុងការរក្សាមតកសាសន៍ដោយលិខិតសម្ងាត់ និងសាក្សីដែលជាអ្នកទទួលបន្ទុកក្នុងការតាក់តែងមតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ជនទាំងនេះត្រូវសរសេរនូវហេតុដែលម្ចាស់បណ្តាំ មិនអាចនិយាយបាន ព្រមទាំងការប្រើវិធីផ្សេងដើម្បីជំនួសការថ្លែងការណ៍ជាផ្ទាល់មាត់ ចូលទៅក្នុងលិខិតមតកសាសន៍ផង។

**២. ម្ចាស់បណ្តាំជាជនដែលមិនអាចស្តាប់បាន**

ក្នុងករណី ម្ចាស់បណ្តាំ និងសាក្សីជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬបុគ្គលផ្សេងទៀត អាចជំនួសការអានឱ្យស្តាប់ ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សី។[58] ថ្វីបើម្ចាស់បណ្តាំមានបំណងធ្វើមតកសាសន៍ តាមទម្រង់ណាមួយដែលច្បាប់បានកំណត់ ដែលតម្រូវឱ្យមានការអាន ឬ សូត្រឡើងវិញនូវខ្លឹមសារនៃមតកសាសស៍ដែលសារការី ឬ បុគ្គលផ្សេងទៀត ដែលបានសរសេរតាមសម្តីរបស់ម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំ និងសាក្សី បែរជាមនុស្សថ្លង់មិនអាចស្តាប់បាន នោះត្រូវមានវត្តមានរបស់អ្នកបកប្រែម្នាក់ទៀត ដើម្បីចូលរួមបកប្រែនូវសម្តីរបស់សារការី ឬ បុគ្គលផ្សេងទៀតដែលច្បាប់បានកំណត់ ជាភាសាកាយវិការឱ្យ ម្ចាស់បណ្តាំ និងសាក្សី។ ក្នុងករណីនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលជាអ្នកទទួលបន្ទុកសរសេរមតកសាសន៍ ត្រូវសរសេរអំពីហេតុដែលម្ចាស់បណ្តាំមិនអាចស្តាប់បាន នៅក្នុងលិខិតមតកសាសន៍។[59]

**កថាខណ្ឌទី៣៖ មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស**

មិនថាជនជាតិខ្មែររស់នៅទីណាទេ សុទ្ធតែអាចធ្វើមតកសាសន៍តាមទម្រង់ដែលកំណត់ដោយក្រមរដ្ឋប្បវេណីកម្ពុជារួមទាំងទម្រង់ធម្មតា និងទម្រង់ពិសេសដែលម្ចាស់បណ្តាំបានស្ថិតក្នុងស្ថានភាពពិសេស។ ម្ចាស់បណ្តាំមានជម្រើស ក្នុងការធ្វើមតកសាសន៍ តាមទម្រង់ណាមួយបានដោយសេរី។ មតកសាសន៍ដោយលិខិតឯកជន ដែលធ្វើឡើងដោយជនជាតិខ្មែររស់នៅបរទេស បានផ្តល់ភាពងាយស្រួលជាងទម្រង់មតកសាសន៍ផ្សេងទៀត ប្រសិនបើម្ចាស់បណ្តាំមានចំណេះដឹង ចេះសរសេរអក្សរ ដោយម្ចាស់បណ្តាំអាចធ្វើ

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី២

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩ កថាខណ្ឌទី៣

មតកសាសាន៍បានដោយខ្លួនឯង មិនចាំបាច់មានសារការី និងសាក្សីទេ។ ចំណែកឯមតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ ម្ចាស់បណ្តាំក៏អាចធ្វើមតកសសាន៍បានដែរ ប្រសិនបើម្ចាស់បណ្តាំបានរស់នៅទីកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ ព្រោះថា មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវបានធ្វើឡើងនៅចំពោះមុខកុងស៊ុល ហើយកុងស៊ុលត្រូវអនុវត្តនាទីរបស់សារការី។[60]

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨១

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើកាសិក្សាស្រាវជ្រាវ លើទ្រឹស្តីគតិយុត្តដោយផ្អែកលើក្រមរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ នឹងប្រធានបទស្តីពី **ទម្រង់នៃលិខិតមតកសាសន៍ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា** រួចមក ឃើញថា ទម្រង់នៃលិខិតមតកសាន៍ បានបង្កប់នូវលក្ខខណ្ឌ និងទម្រង់ពិសេសផ្សេងៗគ្នាជាច្រើន ដើម្បីឱ្យមានលក្ខណៈសមស្រប ទៅនឹងស្ថានភាពជាក់ស្តែងរបស់ម្ចាស់បណ្តាំ នៅពេលធ្វើមតកសាសន៍។ ការកំណត់នូវទម្រង់នៃមតកសាសន៍នីមួយៗ បានធ្វើឡើងក្នុងគោលបំណង ដើម្បីការពារផលប្រយោជន៍រួម របស់ម្ចាស់បណ្តាំ និងអ្នកដែលទទួលបានផលប្រយោជន៍តាមរយៈមតកសាសន៍តែប៉ុណ្ណោះ។

ការធ្វើមតកសាសន៍ ចាំបាច់ត្រូវធ្វើតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី ព្រោះថា បើការធ្វើមតកសាន៍ បានខ្វះ ឬ មិនត្រូវនឹងទម្រង់ណាមួយ ដែលបានកំណត់ដោយច្បាប់ មតកសាសន៍ ត្រូវចាត់ទុកជាមោឃៈ។ ទោះបីជាការធ្វើមតកសាសន៍តាមទម្រង់ណាមួយក្តី ម្ចាស់បណ្តាំ ត្រូវតែមានសមត្ថភាពក្នុងការធ្វើសកម្មភាព និងសម្ថភាពខាងឆន្ទៈ ពោលគឺម្ចាស់បណ្តាំ ត្រូវតែជានីតិជន និងអនីតិជនដែលទទួលបានអគ្គាធិនភាព និងអាចដឹងអំពីលទ្ធផលនៃសកម្មភាពរបស់ខ្លួនតាមផ្លូវច្បាប់ ទើបអាចធ្វើមតកសាសន៍បាន។

ម្ចាស់បណ្តាំ អាចធ្វើមតកសាសន៍ដោយខ្លួនឯង តាមទម្រង់នៃមតកសាសន៍ដោយលិខិតឯកជន។ ទម្រង់នេះ តម្រូវឱ្យម្ចាស់បណ្តាំ មានចំណេះដឹង និងចេះសរសេរអក្សរ ដោយសារតែម្ចាស់បណ្តាំ ត្រូវសរសេរដោយផ្ទាល់ដៃ នូវខ្លឹមសារនៃមតកសាសន៍ ដោយមិនអាចប្រើប្រាស់នូវម៉ាស៊ីន ដូចជាអង្គុលីលេខ ឬ កុំព្យូទ័របានទេ និងពុំមានអ្នកណាអាចសរសេរជំនួសបានដែរ។ ផ្ទុយទៅវិញ ប្រសិនបើម្ចាស់បណ្តាំ មានបំណងឱ្យតតិយជន ជាអ្នកសរសេរមតកសាសន៍ជំនួស ម្ចាស់បណ្តាំ អាចធ្វើមតកសាសន៍តាមទម្រង់ជាលិខិតយថាភូត និង មតកសាសន៍តាមទម្រង់ជាលិខិតសម្ងាត់បាន។

បន្ថែមពីនេះ មានករណីដែលម្ចាស់បណ្តាំ កំពុងស្ថិតក្នុងស្ថានភាពពិសេស មិនអាចធ្វើមតកសាសន៍បានបានតាមទម្រង់ធម្មតា ក្រមរដ្ឋប្បវេណី ក៏បានកំណត់ពីទម្រង់ជាក់លាក់មួយចំនួនដែលត្រូវអនុវត្តក្នុងករណីពិសេសនីមួយៗ។ មិនតែប៉ុណ្ណោះ ការធ្វើមតកសាសន៍ បានបើកទូលាយដល់ជននៅក្រោមអាណាព្យាបាលទូទៅ និងជនដែលមិនចេះនិយាយ ឬ មិនអាចស្តាប់បាន ក៏អាចធ្វើមតកសាសន៍បានដែរ។ យ៉ាងណាមិញ ម្ចាស់បណ្តាំដែលជាជនជាតិខ្មែរ រស់នៅបរទេស ក៏អាចធ្វើមតកសាសន៍តាមទម្រង់ជាលិខិតយថាភូត និងជាទម្រង់លិខិតសម្ងាត់បានដែរ ប្រសិនបើមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ។

ការសិក្សាអំពីទម្រង់នៃមតកសាសន៍ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី គឺពិតជាមានគុណតម្លៃដ៏វិសេសសវិសាល ក្នុងការបង្កើននូវចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងការធ្វើមតកសាសន៍ ក៏ដូចជាស្វែងយល់ពីបញ្ហាដែលកំពុងកើតមានឡើងនៅក្នុងសង្គមជាក់ស្តែង។ ទម្រង់នៃមតកសាសន៍ គឺជាផ្នែកមួយដ៏សំខាន់ក្នុងរបបនៃសន្តតិកម្មតាមបណ្តាំ ដើម្បីឱ្យមតកសាសន៍ដែលបានធ្វើឡើងត្រឹមត្រូវស្របច្បាប់ និងដើម្បីបង្ការការក្លែងបន្លំណាមួយកើតឡើង ជាពិសេស គឺការសម្រេចនូវឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំ នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព។

ទន្ទឹមនឹងនេះ ប្រសិនបើយើងពិនិត្យឱ្យបានស៊ីជម្រៅទៅលើបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងទម្រង់នៃមតកសាសន៍ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឃើញថា នៅមានចំនុចមួយចំនួន ដែលមានការខ្វះចន្លោះ និងមិនបានកំណត់ជាក់លាក់នៅឡើយ។ ការមិនបានកំណត់ច្បាស់លាស់ ក៏ជាកត្តាដែលអាចធ្វើឱ្យទម្រង់នៃមតកសាសន៍ដែលបានធ្វើដោយម្ចាស់បណ្តាំ ងាយនឹងមានការក្លែងបន្លំ និងបាត់បង់ផងដែរ។ ជាក់ស្តែង នៅក្នុងលក្ខខណ្ឌទម្រង់នៃមតកសាសន៍ បញ្ញត្តិច្បាប់បានកំណត់ថា ម្ចាស់បណ្តាំត្រូវចុះហត្ថលេខានៅលើមតកសាន៍ដែលម្ចាស់បណ្តាំបានធ្វើ។ ការកំណត់ឱ្យចុះហត្ថលេខា មិនបានបញ្ជាក់ន័យច្បាស់លាស់ថាត្រូវចុះហត្ថលេខាយ៉ាងដូចម្តេចទេ ក្នុងន័យនេះ អាចចុះហត្ថលេខាត្រឹមទំព័រចុងក្រោយ ឬយ៉ាងណា។ មានករណីដែលម្ចាស់បណ្តាំ ធ្វើមតកសាសន៍ ដោយមានច្រើនទំព័រ ហេតុនេះ ប្រសិនបើទម្រង់នៃមតកសាសន៍ដែលបានកំណត់ដោយច្បាប់ពុំបានកំណត់ឱ្យបានច្បាស់លាស់ទេ ម្ចាស់បណ្តាំ គ្រាន់តែចុះហត្ថលេខាត្រង់ទំព័រចុងក្រោយ នឹងមានសុពលភាពតាមផ្លូវច្បាប់ ដូច្នេះ ទំព័រនៃមតកសាសន៍ដែលមិនបានចុះហត្ថលេខាអាចត្រូវបានកែប្រែ ឬ ក្លែងបន្លំបាន។ ម៉្យាងវិញទៀត ការចុះហត្ថលេខានៅក្នុងសង្គមយើងបច្ចុប្បន្ន នៅមិនទាន់មានការអនុវត្តបានល្អប្រសើរនៅឡើយទេ ប្រជាពលរដ្ឋមួយចំនួន ដែលជាអ្នករកស៊ី ឬ ធ្វើស្រែចំការជាដើម មិនយល់ថាអ្វីជាហត្ថលេខា ឬ មិនចេះចុះហត្ថលេខានោះទេ។ គំនូសហត្ថលេខា ត្រូវបានផ្លាស់ប្តូរដោយសេរី ព្រោះថាមិនមានប្រព័ន្ធគ្រប់គ្រង ឬ បញ្ញត្តិច្បាប់ដែលចងជាកាតព្វកិច្ចនោះទេ ហេតុនេះ ការចុះហត្ថលេខាលើមតកសាសន៍តែម្យ៉ាង មិនអាចបញ្ជាក់ច្បាស់ពីឆន្ទៈរបស់ម្ចាស់បណ្តាំនោះទេ។

បន្ថែមពីនេះ ទោះបីជា ក្រមរដ្ឋប្បវេណី បានប្រកាសឱ្យប្រើប្រាស់តាំងពីឆ្នាំ២០០៧ ក៏ពិតមែន ប៉ុន្តែបញ្ញត្តិដែលពាក់ព័ន្ធនឹងទម្រង់មតកសាសន៍ដែលបានកំណត់ដោយច្បាប់ ហាក់មិនទាន់បានបើកទូលំទូលាយដល់ប្រជាពលរដ្ឋនៅឡើយ។ ប្រជាពលរដ្ឋហាក់នៅមិនទាន់យល់ច្បាស់ចំពោះទម្រង់នីមួយៗនៃមតកសាសន៍ដែលម្ចាស់បណ្តាំអាចធ្វើ ដើម្បីបង្កើតសុពលភាពតាមផ្លូវច្បាប់។ ប្រជាពលរដ្ឋភាគច្រើន មិនបានធ្វើមតកសាសន៍ត្រឹមត្រូវតាមទម្រង់ច្បាប់នោះទេ ពោលគឺភាគច្រើនគ្រាន់តែហៅកូនចៅមកធ្វើបណ្តាំដោយផ្ទាល់

មាត់ មិនមានការធ្វើជាលិខិតជាលាយលក្ខណ៍អក្សរ ឬ ធ្វើតាមលក្ខខណ្ឌទម្រង់ដែលកំណត់ដោយច្បាប់នោះទេ។ បណ្តាំដែលបានធ្វើក្នុងទម្រង់ជាផ្ទាល់មាត់ មិនត្រូវបានចាត់ទុកថាជាទម្រង់ណាមួយដែលកំណត់ដោយក្រម រដ្ឋប្បវេណីនោះទេ ហេតុនេះបណ្តាំប្រភេទនេះមិនមានអានុភាពតាមផ្លូវច្បាប់ឡើយ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ជុំវិញប្រធានបទស្តីពី **ទម្រង់នៃលិខិតមតក-សាសន៍ក្នុងក្រមរដ្ឋប្បវេណី** រួចមក ជារួមឃើញថា ទម្រង់នៃលិខិតមតកសាសន៍ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីមានភាពច្បាស់លាស់ ប៉ុន្តែនៅមានចំណុចខ្វះខាតមួយចំនួន គួរបំពេញបន្ថែម ដើម្បីឱ្យការធ្វើមតកសាសន៍កាន់តែមានភាពត្រឹមត្រូវ និងពិតប្រាកដតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។ បន្ថែមពីនេះ ការអនុវត្តលើបញ្ញត្តិដែលពាក់ព័ន្ធនឹងទម្រង់នៃមតកសាសន៍នៅក្នុងប្រទេសយើង ក៏មិនទាន់មានភាពទូលំទូលាយនៅឡើយ ហេតុដូច្នេះ ដើម្បីឱ្យទម្រង់នៃមតកសាសន៍កាន់ច្បាស់លាស់ និងជម្រុញការអនុវត្តឱ្យកាន់តែរលូន និងមានភាពល្អប្រសើរជាងមុនទៀត នាងខ្ញុំសូមចូលរួមមតិយោបល់ដូចខាងក្រោម៖

១. ក្រសួងយុត្តិធម៌ ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធ គប្បីពិនិត្យមើលបន្ថែមលើបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងទម្រង់នៃមតកសាសន៍ ត្រង់ចំណុចការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ ដោយធ្វើវិសោធនកម្មបំពេញបន្ថែម ទៅលើចំណុច ការចុះហត្ថលេខា មកជា ការចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃនិងសរសេរនាមខ្លួន ឬនាមត្រកូល វិញ ហើយបន្ថែមត្រង់ការចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃនៅគ្រប់ទំព័រនៃមតកសាសន៍។ ការធ្វើបែបនេះ អាចបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមិនចេះចុះហត្ថលេខា ដោយជំនួសការចុះហត្ថលេខាដោយស្នាមមេដៃបាន ហើយការចុះហត្ថលេខា ឬស្នាមមេដៃ នៅគ្រប់ទំព័រនឹងធ្វើឱ្យមតកសាសន៍កាន់តែមានភាពពិតប្រាកដ។

២. ក្រសួងយុត្តិធម៌គួរគប្បីធ្វើការផ្សព្វផ្សាយ អំពីរបបនៃសន្តតិកម្មតាមមតកសាសន៍ ជាពិសេសពាក់ព័ន្ធនឹងទម្រង់នៃលិខិតមតកសាសន៍ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី ឱ្យកាន់តែទូលំទូលាយដល់សាធារណជន ដើម្បីឱ្យដឹងពីទម្រង់បែបបទនៃការធ្វើមតកសាសន៍ ប្រកបដោយប្រសិទ្ធភាព។ ដោយធ្វើការពង្រីកនូវការផ្សព្វផ្សាយ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ជាពិសេសការបង្កើតនូវសិក្ខាសាលាបន្ថែមជូនដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានដឹង និងយល់កាន់តែច្បាស់ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងទម្រង់នៃមតកសាសន៍ ដែលត្រូវបានកំណត់ដោយច្បាប់ ដើម្បីជាប្រយោជន៍ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋផ្ទាល់។

# ឯកសារពិគ្រោះ


## ១. អត្ថបទច្បាប់

១.១. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

១.២. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

## ២. អត្ថបទពិគ្រោះ

២.១. ក្រសួងយុត្តិធម៌, ឆ្នាំ២០០៩, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១ គន្ថីទី១-ទី៣, ភ្នំពេញ។

២.២. ក្រសួងយុត្តិធម៌, ឆ្នាំ២០១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ២ គន្ថីទី៤, ភ្នំពេញ។

២.៣. ក្រសួងយុត្តិធម៌, ឆ្នាំ២០១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី៨-ទី៩, ភ្នំពេញ។

២.៤. រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឆ្នាំ២០១៣, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ ១, ភ្នំពេញ, ការកែសម្រួលលើការបោះពុម្ពលើកទី១។

២.៥. រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឆ្នាំ២០១៧, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ ៣, ភ្នំពេញ, ការកែសម្រួលលើការបោះពុម្ពលើកទី១។

២.៦. អ៊ីវ ប៉ូលី, ទេព បូផល, ឆ្នាំ២០១៧, មតកសាសន៍

## ៣. គេហទំព័រ

៣.១.https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_04_01.pdf

៣.២. https://drive.google.com/file/d/1Z1aPFMXz-JOpT0Ili_raqyLN9ypgy8cB/view

៣.៣.https://www.rfi.fr/km/chronique-bilingue-hel-sambath-testament-02-08-2018